ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍ប្រចាំឆ្នាំ ២០១០
# ប្រព័ន្ធស្ថិតិជាតិកម្ពុជា

របាយការណ៍ប្រចាំឆ្នាំ ២០១០ ប្រព័ន្ធស្ថិតិជាតិកម្ពុជា

**រៀបចំដោយ**

**វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ**

**រាជធានីភ្នំពេញ ខែ សីហា ឆ្នាំ ២០១១**

# បុព្វកថា

ខ្ញុំមានក្តីសោមនស្សរីករាយក្រៃលែង ក្នុងការបង្ហាញរបាយការណ៍ប្រចាំឆ្នាំលើកដំបូងស្តីពីប្រព័ន្ធស្ថិតិជាតិ ចាប់តាំងពីអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង ត្រូវបានអនុម័តនៅខែកក្កដា ឆ្នាំ២០១០។ យោងតាមអនុក្រឹត្យ ក្នុងរយៈពេល ១២ ខែ បន្ទាប់ពីអនុក្រឹត្យចូលជាធរមាន ក្រសួងផែនការ ត្រូវបញ្ជូនរបាយការណ៍ប្រចាំឆ្នាំទៅទីស្តីការគណៈរដ្ឋមន្ត្រី។ វិទ្យាស្ថានជាតិស្ថិតិ ជាស្ថាប័នស្ថិតិជាតិផ្លូវការ និងជាអគ្គនាយកដ្ឋានចំណុះក្រសួងផែនការបានរៀបចំរបាយការណ៍នេះ ជាមួយការគាំទ្រដ៏មានតម្លៃពីក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធទៅនឹងប្រព័ន្ធស្ថិតិជាតិ។

របាយការណ៍ប្រចាំឆ្នាំ ជាលក្ខខណ្ឌចាំបាច់សម្រាប់វិទ្យាស្ថានជាតិស្ថិតិ ក្នុងការចាប់ផ្តើមធ្វើការងារជាមួយការសម្របសម្រួលនៃប្រព័ន្ធស្ថិតិជាតិកម្ពុជា។ របាយការណ៍ប្រចាំឆ្នាំលើកដំបូងនេះគឺជាទិន្នន័យដ៏មានតម្លៃសម្រាប់រៀបចំផែនការសកម្មភាពសម្របសម្រួលនាពេលអនាគត។ រាជរដ្ឋាភិបាលកម្ពុជានឹងទទួលបាននូវទស្សនៈដ៏ល្អមួយ នៃអ្វីដែលជាស្ថិតិផ្លូវការបានផលិតដែលអាចយកមកប្រើប្រាស់សម្រាប់រៀបចំគោលនយោបាយ និងសកម្មភាពស្ថិតិដែលត្រូវការនាពេលអនាគតចំពោះការតបស្នងដល់ព័ត៌មានដែលបានផ្តល់ឲ្យដោយក្រសួង ស្ថាប័នពាក់ព័ន្ធ។

ក្នុងនាមនៃរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមឆ្លៀតឱកាសនេះ ដើម្បីថ្លែងអំណរគុណដល់ទីភ្នាក់ងារដើម្បីអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) ចំពោះការគាំទ្រផ្នែកហិរញ្ញវត្ថុ និងស្ថិតិស៊ុយអែត ចំពោះការគាំទ្រផ្នែកបច្ចេកទេសក្នុងការរៀបចំរបាយការណ៍នេះ។ ខ្ញុំក៏សូមអរគុណដល់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានផ្តល់ឲ្យវិទ្យាស្ថានជាតិស្ថិតិ នូវព័ត៌មានសម្រាប់របាយការណ៍នេះ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**
**ប្រធាន ក្រុមប្រឹក្សាស្ថិតិ**

**ឆាយ ថន**

ក្រសួងផែនការ
រាជធានីភ្នំពេញ
ខែ សីហា ឆ្នាំ ២០១១

# អារម្ភកថា

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ មានភារកិច្ចធ្វើការសម្របសម្រួលនៃប្រព័ន្ធស្ថិតិជាតិ។ យោងតាមអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង ដែលអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានាខែកក្កដា ឆ្នាំ ២០១០ ការងារមួយក្នុងចំណោមការងារនានារបស់វិទ្យាស្ថានជាតិស្ថិតិ និងក្រសួងផែនការ គឺបង្ហាញរបាយការណ៍ប្រចាំឆ្នាំដល់ទីស្តីការគណៈរដ្ឋមន្ត្រី។ នេះគឺជារបាយការណ៍លើកដំបូងដែលបានរៀបចំដោយវិទ្យាស្ថានជាតិស្ថិតិ។ ព័ត៌មាននៅក្នុងរបាយការណ៍នេះ ត្រូវបានប្រមូលពីក្រសួងស្ថាប័នពាក់ព័ន្ធចំនួន ២៧ (ក្រសួង ក្រុមប្រឹក្សា ធនាគារជាតិនៃកម្ពុជា) ដែលទទួលខុសត្រូវលើស្ថិតិផ្លូវការដែលបានចាត់តាំង។

យើងខ្ញុំសូមថ្លែងអំណរគុណដល់សមាជិកនៃគណៈកម្មាធិការសម្របសម្រួលស្ថិតិ និងមន្ត្រីនៅផ្នែកស្ថិតិផ្លូវការដែលបានចាត់តាំងនៅក្នុងក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានជួយដល់វិទ្យាស្ថានជាតិស្ថិតិក្នុងការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិកម្ពុជា។ យើងខ្ញុំក៏សូមថ្លែងអំណរគុណ ចំពោះការងារដែលបានធ្វើដោយមន្ត្រីវិទ្យាស្ថានជាតិស្ថិតិ និងចំពោះបុគ្គលទាំងអស់ដែលធ្វើការដោយខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ខ្ពស់ក្នុងការបង្កើនគុណភាពស្ថិតិផ្លូវការដែលបានចាត់តាំងនៅកម្ពុជា។ លើសពីនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ស្ថិតិស៊ុយអែត ដែលបានជួយផ្នែកគ្រប់គ្រង និងបច្ចេកទេស។

មន្ត្រីទំនាក់ទំនងសម្រាប់របាយការណ៍នេះមានលោក ហ៊ាង កាណុល លោកស្រី សូរ្យ សុវណ្ណចរិយា លោកស្រី នង សុគន្ធាវី និងកញ្ញា ស៊ុយ សុធារ៉ា ។

**អគ្គនាយក វិទ្យាស្ថានជាតិស្ថិតិ**
**ប្រធាន គណៈកម្មាធិការសម្របសម្រួលស្ថិតិ**

**សន ស៊ីថន**

វិទ្យាស្ថានជាតិស្ថិតិ
ក្រសួងផែនការ
ខែ សីហា ឆ្នាំ ២០១១

# មាតិកា


ទំព័រ

បុព្វកថា ........ ១
អារម្ភកថា ........ ២
សង្ខេប ........ ៥
ប្រព័ន្ធស្ថិតិជាតិកម្ពុជា ........ ៨
១ សាវតារ ........ ៨
១.១ ការសម្រេច និងការអនុវត្តន៍ច្បាប់ ........ ៩
១.២ ការអភិវឌ្ឍន៍សមត្ថភាពបច្ចុប្បន្នរបស់វិទ្យាស្ថានជាតិស្ថិតិ ........ ១០
១.៣ ការសម្របសម្រួលដោយកិច្ចសហប្រតិបត្តិការទូលំទូលាយ គឺជាមធ្យោបាយដ៏សំខាន់ ........ ១២
**២ ច្បាប់ និងអនុក្រឹត្យ ........ ១២**
២.១ ច្បាប់ស្តីពីស្ថិតិ ........ ១២
២.២ អនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ ........ ១៣
២.៣ អនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង ........ ១៤
៣ រចនាសម្ព័ន្ធនៃប្រព័ន្ធស្ថិតិជាតិ ........ ១៥
៣.១ និយមន័យនៃស្ថិតិផ្លូវការដែលបានចាត់តាំង ........ ១៥
៣.២ លក្ខណៈទូទៅនៃប្រព័ន្ធស្ថិតិជាតិ ........ ១៦
៣.៣ ការងារ និងសមាសភាពក្រុមប្រឹក្សាស្ថិតិ ........ ១៧
៣.៤ ការងារ និងសមាសភាពគណៈកម្មាធិការសម្របសម្រួលស្ថិតិ ........ ១៨
៣.៤.១ ការប្រជុំគណៈកម្មាធិការ ........ ១៩
៣.៥ ការងារសម្របសម្រួលសម្រាប់វិទ្យាស្ថានជាតិស្ថិតិ យោងតាមច្បាប់ ........ ២១
៣.៦ ការងារសម្រាប់អង្គភាពស្ថិតិដែលបានចាត់តាំង ........ ២៣
**៤ តម្រូវការស្ថិតិផ្លូវការដែលបានចាត់តាំង ........ ២៤**
៥ សកម្មភាពក្នុងប្រព័ន្ធស្ថិតិជាតិសម្រាការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ នៅឆ្នាំ ២០១០ ........ ២៦
៥.១ អនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង ........ ២៦
៥.២ សន្និធិសមត្ថភាព (Competence Inventory) ........ ២៨
៥.៣ ការប្រមូលម៉េតាទិន្នន័យ ........ ២៨
៥.៤ សិក្ខាសាលាសម្រាប់សមាជិកគណៈកម្មាធិការសម្របសម្រួលស្ថិតិ ........ ២៩
៦ ប្រព័ន្ធស្ថិតិជាតិឆ្នាំ ២០១០ ........ ២៩
៦.១ ធនធាននៅក្នុងប្រព័ន្ធស្ថិតិជាតិ ឆ្នាំ ២០១០ ........ ២៩
៦.២ កម្រិតសមត្ថភាពក្នុងប្រព័ន្ធស្ថិតិជាតិ នៅខែ វិច្ឆិកា ឆ្នាំ ២០១០ ........ ២៩
៦.៣ ការបោះពុម្ពផ្សាយក្នុងប្រព័ន្ធស្ថិតិជាតិ ........ ៣០

៦.៤ វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង ................................ ៣១
៦.៤.១ វិទ្យាស្ថានជាតិស្ថិតិ ................................ ៣១
៦.៤.២ ទីស្ដីការគណៈរដ្ឋមន្ត្រី ................................ ៣៤
៦.៤.៣ ក្រសួងមហាផ្ទៃ ................................ ៣៥
៦.៤.៤ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ................................ ៣៦
៦.៤.៥ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ................................ ៣៧
៦.៤.៦ ក្រសួងអភិវឌ្ឍន៍ជនបទ ................................ ៣៩
៦.៤.៧ ក្រសួងពាណិជ្ជកម្ម ................................ ៤០
៦.៤.៨ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ................................ ៤០
៦.៤.៩ ក្រសួងអប់រំ យុវជន និងកីឡា ................................ ៤១
៦.៤.១០ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ................................ ៤២
៦.៤.១១ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ................................ ៤៣
៦.៤.១២ ក្រសួងបរិស្ថាន ................................ ៤៣
៦.៤.១៣ ក្រសួងធនធានទឹក និងឧតុនិយម ................................ ៤៤
៦.៤.១៤ ក្រសួងព័ត៌មាន ................................ ៤៥
៦.៤.១៥ ក្រសួងយុត្តិធម៌ ................................ ៤៥
៦.៤.១៦ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ................................ ៤៦
៦.៤.១៧ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ................................ ៤៧
៦.៤.១៨ ក្រសួងសុខាភិបាល ................................ ៤៨
៦.៤.១៩ ក្រសួងសាធារណការ និងដឹកជញ្ជូន ................................ ៤៨
៦.៤.២០ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ................................ ៤៩
៦.៤.២១ ក្រសួងទេសចរណ៍ ................................ ៥០
៦.៤.២២ ក្រសួងធម្មការ និងសាសនា ................................ ៥១
៦.៤.២៣ ក្រសួងកិច្ចការនារី ................................ ៥២
៦.៤.២៤ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ................................ ៥២
៦.៤.២៥ រដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍ស៊ីវិល ................................ ៥៣
៦.៤.២៦ រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ ................................ ៥៤
៦.៤.២៧ ធនាគារជាតិនៃកម្ពុជា ................................ ៥៥
៦.៤.២៨ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ................................ ៥៦

**ឧបសម្ព័ន្ធ ១ ច្បាប់សម្រាប់ប្រព័ន្ធស្ថិតិជាតិ ................................ ៥៨**
ច្បាប់ស្តីពីស្ថិតិ ................................ ៥៩
អនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ ................................ ៧១
អនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង ................................ ៨៩

**ឧបសម្ព័ន្ធ ២ការបោះពុម្ព និងផលិតផលអេឡិចត្រូនិច ................................ ១០១**
វិទ្យាស្ថានជាតិស្ថិតិ ................................ ១០២
អង្គភាពស្ថិតិ ................................ ១០៦

# សង្ខេប

របាយការណ៍លើកដំបូងស្តីពីប្រព័ន្ធស្ថិតិជាតិ ដែលរៀបចំដោយវិទ្យាស្ថានជាតិស្ថិតិគឺជាតម្រូវការ នៃអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង ដែលបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ ២០១០។ វាផ្តល់នូវទស្សនៈរួមនៃប្រព័ន្ធសម្រាប់ស្ថិតិផ្លូវការដែលបានចាត់តាំងនៅកម្ពុជា និងសកម្មភាពនានាដែលបានអនុវត្តនៅឆ្នាំ ២០១០ ដោយវិទ្យាស្ថានជាតិស្ថិតិ និងអ្នកផលិតស្ថិតិនៅក្នុងប្រព័ន្ធស្ថិតិជាតិ។

នៅឆ្នាំ ២០១០ ក្រៅពីវិទ្យាស្ថានជាតិស្ថិតិ ប្រព័ន្ធស្ថិតិជាតិរួមមានក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធចំនួន ២៧ ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជា។ ក្រសួងស្ថាប័នទាំងអស់នេះ ទទួលខុសត្រូវលើស្ថិតិផ្លូវការដែលបានចាត់តាំងនៅកម្ពុជាដូចបានកំណត់នៅក្នុងអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង។ វិទ្យាស្ថានជាតិស្ថិតិទទួលខុសត្រូវលើការសម្របសម្រួលប្រព័ន្ធ។ ផលិតផលស្ថិតិត្រូវបានធ្វើវិមជ្ឈការ។

ឧបសគ្គ និងអត្ថប្រយោជន៍របស់ប្រព័ន្ធស្ថិតិជាតិវិមជ្ឈការតម្រូវឲ្យមានការសម្របសម្រួលការងារដែលបានដំណើរការនៅក្នុងអង្គភាពផ្សេងៗគ្នាក្នុងប្រព័ន្ធ។

តាមច្បាប់ស្ថិតិដែលបានបង្កើតឡើង[១] និងការអនុវត្តន៍ច្បាប់នេះ វិទ្យាស្ថានជាតិស្ថិតិបានចាប់ផ្តើមរៀបចំរចនាសម្ព័ន្ធឡើងវិញដោយបន្ថែមបីនាយកដ្ឋានទៀត រួមទាំងនាយកដ្ឋានស្តង់ដារស្ថិតិ និងវិភាគស្ថិតិដែលទទួលខុសត្រូវលើសកម្មភាពសម្របសម្រួលនៅវិទ្យាស្ថានជាតិស្ថិតិ។

ច្បាប់ស្តីពីស្ថិតិ គ្រប់គ្រងរាល់ការងារដែលទាក់ទងដល់ទិន្នន័យស្ថិតិ និងមានវិសាលភាពគ្របដណ្តប់ទូទាំងព្រះរាជាណាចក្រកម្ពុជាទាំងមូល។ យោងតាមច្បាប់នេះ មានអនុក្រឹត្យចំនួនពីរដែលកំណត់ការងារសម្រាប់ប្រព័ន្ធស្ថិតិជាតិ។ វិទ្យាស្ថានជាតិស្ថិតិក៏មានអនុក្រឹត្យមួយ ស្តីពីការរៀបចំរចនាសម្ព័ន្ធរបស់វិទ្យាស្ថានជាតិស្ថិតិដែលមិនបានពណ៌នាក្នុងរបាយការណ៍នេះ។ ច្បាប់ស្តីពីស្ថិតិបានកំណត់ថា វិទ្យាស្ថានជាតិស្ថិតិស្ថិតក្រោមឱវាទក្រសួងផែនការមានភារកិច្ចកសាងគោលនយោបាយស្ថិតិផ្លូវការក្នុងការបង្កើតប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយ ដែលគ្របដណ្តប់ស្ថិតិផ្លូវការដែលបានចាត់តាំងទាំងអស់ និងអង្គភាពស្ថិតិក្នុងក្រសួង និងស្ថាប័ន។

ច្បាប់ស្តីពីស្ថិតិក៏កំណត់ផងដែរថា ក្រុមប្រឹក្សាស្ថិតិដែលមានរដ្ឋមន្ត្រីក្រសួងផែនការជាប្រធានត្រូវបានបង្កើតឡើងដើម្បីផ្តល់ប្រឹក្សាជូនក្រសួងផែនការ ក្នុងការជំរុញកិច្ចអភិវឌ្ឍន៍ប្រព័ន្ធស្ថិតិជាតិ។ ដូចគ្នានេះដែរ គណៈកម្មាធិការសម្របសម្រួលស្ថិតិដែលមានអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិជាប្រធាន

[១] ឧបសម្ព័ន្ធ ១ ៖ ច្បាប់សម្រាប់ប្រព័ន្ធស្ថិតិជាតិ

ត្រូវបានបង្កើតឡើងដើម្បីជួយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ក្នុងការសម្របសម្រួលផ្នែកបច្ចេកទេសស្ថិតិផ្លូវការរបស់រាជរដ្ឋាភិបាល។

អនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ គ្រប់គ្រងរាល់ការងាររៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ កាតព្វកិច្ចស្ថិតិ និងការងារទាំងឡាយដែលពាក់ព័ន្ធដើម្បីអនុវត្តច្បាប់ស្តីពីស្ថិតិនៃព្រះរាជាណាចក្រកម្ពុជា។

វិទ្យាស្ថានជាតិស្ថិតិ ជាស្ថាប័នសម្រាប់ធ្វើគោលនយោបាយស្ថិតិផ្លូវការរបស់រាជរដ្ឋាភិបាលក្នុងការបង្កើត និងដឹកនាំប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយ ដែលគ្របដណ្តប់ស្ថិតិផ្លូវការដែលបានចាត់តាំងទាំងអស់របស់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល និងអង្គភាពស្ថិតិខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីស្ថិតិនៅគ្រប់ឃុំ សង្កាត់។

អនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង មានគោលដៅកំណត់ឲ្យក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ប្រមូល និងចងក្រងស្ថិតិផ្លូវការដែលបានចាត់តាំងទៅតាមវិស័យរបស់ខ្លួន។ អនុក្រឹត្យបានកំណត់ថា អង្គភាពស្ថិតិត្រូវទទួលខុសត្រូវលើការអង្កេត។ ចំនួនទាំងអស់មាន ២៧ ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ ដោយរាប់បញ្ចូលទាំងធនាគារជាតិនៃកម្ពុជាមានភារកិច្ចទទួលខុសត្រូវលើស្ថិតិផ្លូវការដែលបានចាត់តាំងក្រៅពីស្ថិតិដែលផលិតដោយវិទ្យាស្ថានជាតិស្ថិតិ។

អនុក្រឹត្យបានចែងថា រាល់ការប្រមូលទិន្នន័យដែលមានស្រាប់ ត្រូវចុះបញ្ជីនៅវិទ្យាស្ថានជាតិស្ថិតិ។ ការប្រមូលទិន្នន័យដែលបានគ្រោងទុក និងថ្មីក៏ត្រូវចុះបញ្ជីផងដែរ មុននឹងចាប់ផ្តើមអនុវត្តការងារ។ បញ្ជីនៃរាល់ការប្រមូលទិន្នន័យដែលមានស្រាប់ ការចំណាយ និងស្ថានភាពនៃការប្រមូលទិន្នន័យនីមួយៗត្រូវបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី នៅឆ្នាំដំបូងបន្ទាប់ពីអនុក្រឹត្យចូលជាធរមាន។ បញ្ជីត្រូវធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ។

អង្គភាពស្ថិតិដែលបានចាត់តាំងនៅតាមក្រសួង ស្ថាប័នរាជរដ្ឋាភិបាលត្រូវបញ្ជូននូវរាល់ព័ត៌មាន និងទិន្នន័យស្ថិតិដែលផលិតបានជាទម្រង់អេឡិចត្រូនិច និងជាសៀវភៅទៅវិទ្យាស្ថានជាតិស្ថិតិ និងទៅទីស្តីការគណៈរដ្ឋមន្ត្រីឲ្យបានទៀងទាត់ និងទាន់ពេលវេលា។

សរុបមន្ត្រីជាង ៦០០នាក់ នៅក្នុងក្រសួងពាក់ព័ន្ធ វិទ្យាស្ថានជាតិស្ថិតិ និងធនាគារជាតិនៃកម្ពុជាដែលបានធ្វើការងារជាមួយស្ថិតិផ្លូវការដែលបានចាត់តាំងនៅឆ្នាំ ២០១០។ ជិត ៥២ ភាគរយនៃមន្ត្រីទាំងនោះធ្វើការនៅវិទ្យាស្ថានជាតិស្ថិតិ។

នៅឆមាសទីពីរឆ្នាំ ២០១០ ការអង្កេតសន្និធិសមត្ថភាពមន្ត្រីស្ថិតិក្នុងប្រព័ន្ធស្ថិតិជាតិត្រូវបានដំណើរការ បានឲ្យដឹងថាប្រមាណពាក់កណ្តាលនៃមន្ត្រីធ្វើការជាមួយស្ថិតិផ្លូវការដែលបានចាត់តាំងដែលមានកម្រិតសិក្សា ហើយបង្ហាញថាមានតែមួយភាគបីនៃមន្ត្រីប៉ុណ្ណោះ មានជំនាញគ្រប់គ្រាន់ដើម្បី

អនុវត្តការងារក្នុងអង្គភាពស្ថិតិមួយ។ មន្ត្រីមួយចំនួនផ្សេងទៀតខ្វះខាតជំនាញខាងព័ត៌មានវិទ្យា (ICT) និងជំនាញខាងភាសាអង់គ្លេស ហើយក៏ខ្វះខាតផងដែរខាងចំណេះដឹងស្ថិតិមូលដ្ឋាន។

នៅឆ្នាំ ២០១០ មានរបាយការណ៍ ៥០ ប្រភេទខុសៗគ្នា ទោះបីមានរយៈពេលខុសគ្នាក៏ដោយ ក៏ត្រូវបានបោះពុម្ពផ្សាយដោយយោងតាមរបាយការណ៍អំពីសមត្ថភាពមន្ត្រីស្ថិតិក្នុងប្រព័ន្ធស្ថិតិជាតិ។ របាយការណ៍ភាគច្រើនគឺជារបាយការណ៍ប្រចាំឆ្នាំ ប៉ុន្តែក៏មានរបាយការណ៍ប្រចាំត្រីមាស ឬប្រចាំខែផងដែរ ត្រូវបានបោះពុម្ពផ្សាយ។

ទិន្នន័យដែលប្រមូលដោយប្រព័ន្ធស្ថិតិជាតិមិនបានបោះពុម្ពផ្សាយពេញលេញឡើយ ទោះបីស្ថិតិផ្លូវការដែលបានចាត់តាំងតម្រូវឲ្យបោះពុម្ពផ្សាយដល់អ្នកប្រើប្រាស់ទាំងអស់ក៏ដោយ។ ការងារនេះត្រូវកែលម្អក្នុងឆ្នាំ ២០១១។

# ប្រព័ន្ធស្ថិតិជាតិកម្ពុជា

## ១ សាវតារ

ប្រព័ន្ធស្ថិតិជាតិត្រូវបានឲ្យនិយមន័យនៅក្នុងច្បាប់ស្តីពីស្ថិតិ (មាត្រា ២) "ជាសមាហរណកម្ម នៃទិន្នន័យស្ថិតិថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធស្ថិតិរួមបញ្ចូលទាំងទិន្នន័យស្ថិតិផ្លូវការ និងកម្មវិធីស្ថិតិជាតិ រចនាសម្ព័ន្ធស្ថិតិ និងអង្គភាពស្ថិតិក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ព្រមទាំងមន្ត្រីស្ថិតិ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត"។

របាយការណ៍ប្រចាំឆ្នាំស្តីពីប្រព័ន្ធស្ថិតិជាតិ ជាតម្រូវការដោយអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង ដែលអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ ២០១០។ របាយការណ៍ប្រចាំឆ្នាំនេះគឺជារបាយការណ៍ដំបូងគេបង្អស់ ដែលបានរៀបចំដោយវិទ្យាស្ថានជាតិស្ថិតិ ហើយនឹងផ្តល់នូវទស្សនៈរួមមួយនៃប្រព័ន្ធសម្រាប់ស្ថិតិផ្លូវការដែលបានចាត់តាំងនៅកម្ពុជា និងសកម្មភាពដែលបានអនុវត្តនៅឆ្នាំ ២០១០ ដោយវិទ្យាស្ថានជាតិស្ថិតិ និងអ្នកផលិតស្ថិតិក្នុងប្រព័ន្ធស្ថិតិជាតិ។

នៅឆ្នាំ ២០១០ ក្រៅពីវិទ្យាស្ថានជាតិស្ថិតិ ប្រព័ន្ធស្ថិតិជាតិរួមមាន ២៧ ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជា។ ក្រសួង និងស្ថាប័នទាំងអស់នេះមានភារកិច្ចទទួលខុសត្រូវលើស្ថិតិផ្លូវការដែលបានចាត់តាំងនៅកម្ពុជា ដូចបានកំណត់ក្នុងអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង។ វិទ្យាស្ថានជាតិស្ថិតិមានភារកិច្ចទទួលខុសត្រូវលើការសម្របសម្រួលប្រព័ន្ធ។ ផលិតផលស្ថិតិមានលក្ខណៈវិមជ្ឈការ។ លក្ខណៈនៃប្រព័ន្ធតាមបែបវិមជ្ឈការរួមមានដូចខាងក្រោម ៖

- ការអង្កេតដែលនឹងត្រូវធ្វើ និងអថេរដែលត្រូវប្រើប្រាស់ត្រូវបានសម្រេចនៅតាមស្ថាប័នផ្សេងៗគ្នា
- ប្រព័ន្ធចំណាត់ថ្នាក់ វិធីសាស្ត្រ និងស្តង់ដារអាចខុសគ្នានៅក្នុងប្រព័ន្ធ
- លក្ខខណ្ឌ និងទស្សនៈត្រូវបានសម្រេចនៅតាមស្ថាប័នផ្សេងៗគ្នា
- គោលការណ៍នៃបទបង្ហាញខុសគ្នានៅតាមស្ថាប័នផ្សេងៗគ្នា
- ស្ថិតិនឹងត្រូវចេញផ្សាយនៅលើវេបសាយផ្សេងៗគ្នា។

ប្រព័ន្ធស្ថិតិជាតិតាមវិមជ្ឈការមានអត្ថប្រយោជន៍ជាច្រើន ឧទាហរណ៍ អង្គភាពស្ថិតិដែលបានចាត់តាំងអាចធ្វើឯកទេសកម្មក្នុងផ្នែកជាក់លាក់មួយនៃស្ថិតិ និងធ្វើការងារជិតស្និទ្ធជាមួយអ្នកប្រើប្រាស់ទិន្នន័យសំខាន់ៗក្នុងក្រសួងតែមួយ។ ជួនកាលអាចងាយស្រួលក្នុងការស្វែងរកហិរញ្ញប្បទានសម្រាប់ស្ថិតិ ជាងស្ថិតិទាំងអស់ដែលផលិតដោយវិទ្យាស្ថានជាតិស្ថិតិដែលជាអង្គភាពដ៏ធំមួយ។ ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធស្ថិតិជាតិតាមវិមជ្ឈការក៏មានគុណវិបត្តិមួយចំនួនផងដែរ។ ស្ថិតិ និងវិធីសាស្ត្រអាចបង្កើតឡើងដោយឯករាជ្យ ហើយឈានទៅបង្កើតវិធីសាស្ត្រ និយមន័យ និងស្តង់ដារ

ផ្សេងៗគ្នា។ នេះបង្កឲ្យមានបញ្ហាដល់អ្នកប្រើប្រាស់ស្ថិតិដែលចង់ប្រៀបធៀបស្ថិតិតាមពេលវេលា និងទីកន្លែង ឧទាហរណ៍ អ្នកប្រើប្រាស់ចង់ប្រៀបធៀបទិន្នន័យអំពីគ្រួសារពីការអង្កេតផ្សេងៗគ្នា។ វាក៏អាចធ្វើឲ្យមានការប្រើប្រាស់រួមគ្នាពីប្រភពខុសៗគ្នាផងដែរ សម្រាប់គោលបំណងផ្សេងទៀតជៀសជាងការប្រៀបធៀប។ ជាមួយគ្នានេះដែរ វាអាចនឹងមានការលំបាកសម្រាប់អ្នកប្រើប្រាស់ក្នុងការស្វែងរកស្ថិតិ បើមានអ្នកផលិតច្រើន ហើយគ្មានវេបសាយធំមួយសម្រាប់រាល់ស្ថិតិផ្លូវការដែលបានចាត់តាំង។ ហានិភ័យនៃការអង្កេតជាន់គ្នា ក៏ស្ថិតនៅក្នុងកម្រិតខ្ពស់ផងដែរ។ ហេតុដូច្នេះត្រូវធ្វើការសម្របសម្រួលការងាររវាងអង្គភាពស្ថិតិក្នុងប្រព័ន្ធស្ថិតិជាតិ និងវិទ្យាស្ថានជាតិស្ថិតិដែលជាអង្គភាពទទួលខុសត្រូវលើការសម្របសម្រួល។ ច្បាប់ស្តីពីស្ថិតិត្រូវបានអនុម័តនៅខែ ឧសភា ឆ្នាំ ២០០៥ ហើយច្បាប់បានកំណត់ និងរៀបចំស្ថិតិផ្លូវការដែលបានចាត់តាំង។ បច្ចុប្បន្ន ការសម្របសម្រួលការងារស្ថិតិត្រូវបានចាប់ផ្តើមដើម្បីប្រតិបត្តិតាមច្បាប់។ របាយការណ៍នេះនឹងបង្ហាញអំពីការងារដែលបានអនុវត្ត និងស្ថិតិដែលបានផលិតនៅក្នុងប្រព័ន្ធស្ថិតិជាតិ។

## ១.១ ការសម្រេច និងការអនុវត្តន៍ច្បាប់

ច្បាប់ស្តីពីស្ថិតិនៅកម្ពុជា ត្រូវបានអនុម័តនៅខែ ឧសភា ឆ្នាំ ២០០៥ ហើយទាក់ទងទៅនឹងអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិដែលចូលជាធរមាននៅខែ មករា ឆ្នាំ ២០០៧។ ខណៈនោះក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវបានបង្កើតឡើង។ ផែនការមេស្ថិតិឆ្នាំ ២០០៨-២០១៥ ត្រូវបានបង្កើតឡើង និងអនុម័តដោយក្រុមប្រឹក្សាស្ថិតិនៅខែ មេសា ឆ្នាំ ២០០៧ ដែលគាំទ្រប្រព័ន្ធស្ថិតិជាតិក្នុងការអភិវឌ្ឍន៍ស្ថិតិសំខាន់ៗ និងជាបន្ទាន់សម្រាប់កសាងគោលនយោបាយ និងជាមូលដ្ឋានសម្រាប់ការងាររាជរដ្ឋាភិបាលលើការកាត់បន្ថយភាពក្រីក្រ។

នៅឆ្នាំ ២០០៩ វិទ្យាស្ថានជាតិស្ថិតិបានរៀបចំរចនាសម្ព័ន្ធឡើងវិញ ដោយបន្ថែមនាយកដ្ឋានចំនួនបីរួមមាននាយកដ្ឋានបច្ចេកវិទ្យា ទូរគមនាគមន៍ និងព័ត៌មានវិទ្យា នាយកដ្ឋានគណនេយ្យជាតិ និងនាយកដ្ឋានស្តង់ដារស្ថិតិ និងវិភាគស្ថិតិ។ ពេលនោះ កាំអ៊ិនហ្វូ (CAMInfo) ត្រូវបានពង្រីកជាការិយាល័យមួយនៃនាយកដ្ឋានគោលនយោបាយ និងសហប្រតិបត្តិការស្ថិតិ។ នាយកដ្ឋានស្តង់ដារស្ថិតិ និងវិភាគស្ថិតិមានភារកិច្ចទទួលខុសត្រូវលើសកម្មភាពសម្របសម្រួលនៅវិទ្យាស្ថានជាតិស្ថិតិ ខណៈដែលនាយកដ្ឋានគោលនយោបាយ និងសហប្រតិបត្តិការស្ថិតិទទួលខុសត្រូវលើការងារច្បាប់សម្រាប់ប្រព័ន្ធសហប្រតិបត្តិការអន្តរជាតិ និងរៀបចំការប្រជុំក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ។

ក្រៅពីច្បាប់ស្តីពីស្ថិតិដែលអនុម័តនាឆ្នាំ ២០០៥ នៅមានអនុក្រឹត្យនានាដែលកំណត់ឲ្យវិទ្យាស្ថានជាតិស្ថិតិតែមួយនូវក្របខ័ណ្ឌច្បាប់របស់ប្រព័ន្ធស្ថិតិជាតិ ដូចជា ៖

- អនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ ដែលបានអនុម័តនៅឆ្នាំ ២០០៧
- អនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង ដែលបានអនុម័តនៅឆ្នាំ ២០១០។

## ១.២ ការអភិវឌ្ឍន៍សមត្ថភាពបច្ចុប្បន្នរបស់វិទ្យាស្ថានជាតិស្ថិតិ

វិទ្យាស្ថានជាតិស្ថិតិ តាមរយៈការគាំទ្ររបស់ទីភ្នាក់ងារដើម្បីអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) បច្ចុប្បន្នកំពុងពង្រឹងសមត្ថភាពរបស់ខ្លួននៅក្នុងការងារសម្របសម្រួល ដើម្បីជួយដល់អង្គភាពស្ថិតិក្នុងការអនុវត្តន៍ច្បាប់របស់ប្រព័ន្ធស្ថិតិជាតិ។ Sida បានផ្តល់ជំនួយបច្ចេកទេស ឧទាហរណ៍ ការបណ្តុះបណ្តាលតាមរយៈការងារសម្រាប់ការងារសម្របសម្រួល និងការបណ្តុះបណ្តាលជំនាញស្ថិតិ។ សកម្មភាពមួយចំនួនដែលវិទ្យាស្ថានជាតិស្ថិតិត្រូវការអនុវត្តនៅឆ្នាំ ២០១០ និង ២០១១ ដើម្បីឲ្យស្របទៅតាមច្បាប់ គឺជាគម្រោង Sida ដែលកំពុងជួយ ដូចជាការបង្កើតបញ្ជីឈ្មោះស្ថិតិផ្លូវការដែលបានចាត់តាំង និងដំណើរការការងារប្រមូលព័ត៌មានសម្រាប់របាយការណ៍ប្រចាំឆ្នាំបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី។

ទោះជាយ៉ាងណាក៏ដោយ ការងារសំខាន់របស់វិទ្យាស្ថានជាតិស្ថិតិដែលនៅមានក្នុងគម្រោង Sida គឺការអង្កេតសេដ្ឋកិច្ចសង្គមកិច្ច ការវិភាគ និងការផ្សព្វផ្សាយលទ្ធផល។ ជាមួយគ្នានេះដែរ ការកសាងសមត្ថភាពផ្នែកបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន វិធីសាស្រ្តស្ថិតិ និងការអភិវឌ្ឍន៍ធនធានមនុស្សត្រូវបានអនុវត្ត ដែលការងារសម្របសម្រួលនឹងទទួលអត្ថប្រយោជន៍ពីផ្នែកនេះ។ ដោយមានការគាំទ្រពីគម្រោង Sida ប្រព័ន្ធស្ថិតិជាតិត្រូវបានធ្វើសមាហរណកម្មបន្ថែមទៀតក្នុងតំបន់ និងពិភពលោក។ វិទ្យាស្ថានជាតិស្ថិតិបានចូលរួមក្នុងសិក្ខាសាលា ការប្រជុំ ការបណ្តុះបណ្តាល និងកម្មសិក្សាក្នុងតំបន់ និងអន្តរជាតិកាលពីឆ្នាំមុនៗ ដោយមានការឧបត្ថម្ភពីគម្រោង Sida។ សកម្មភាពទាំងនេះនឹងបន្តនៅឆ្នាំ ២០១១។

សកម្មភាពអភិវឌ្ឍន៍សមត្ថភាពសំខាន់ផ្សេងទៀតសម្រាប់វិទ្យាស្ថានជាតិស្ថិតិ ជាមួយការគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) គឺការធ្វើជំរឿនសហគ្រាស ។ ការចុះបញ្ជីសហគ្រាសត្រូវបានធ្វើឡើងនៅឆ្នាំ ២០០៩ និងការអង្កេតសាកល្បងដ៏ធំមួយសម្រាប់ជំរឿនសហគ្រាសបានធ្វើឡើងនៅឆ្នាំ ២០១០ ដែលជាការរៀបចំសម្រាប់ជំរឿនសហគ្រាសឆ្នាំ ២០១១។ JICA ក៏នឹងពង្រឹងការអភិវឌ្ឍន៍សមត្ថភាពស្ថាប័នផងដែរ នៅតាមទីស្នាក់ការក្នុងតំបន់តាមរយៈការផ្តល់កំព្យូទ័រ គ្រឿងបរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធ ការបណ្តុះបណ្តាលតាមរយៈការងារក្នុងការវិភាគ និងការផ្សព្វផ្សាយទិន្នន័យថ្នាក់ក្រោមជាតិ ដូចជាការធ្វើជំរឿនប្រជាជន ការធ្វើជំរឿន និងអង្កេតសហគ្រាស និងរំលឹកឡើងវិញពីតម្រូវការបណ្តុះបណ្តាលរបស់មន្ត្រីស្ថិតិនៅតាមការិយាល័យខេត្ត/ក្រុង នីមួយៗ។ នៅចន្លោះឆ្នាំ ២០០៥ និង ២០០៧ JICA បានធ្វើការបណ្តុះបណ្តាលជំនាញស្ថិតិ

សម្រាប់វិទ្យាស្ថានជាតិស្ថិតិ ខេត្ត និងក្រសួងពាក់ព័ន្ធ។ ក្នុងនោះមានវគ្គបណ្តុះបណ្តាលខាងការណែនាំអំពីស្ថិតិផ្លូវការ ការរៀបចំអង្កេតស្ថិតិ ការកែច្នៃទិន្នន័យស្ថិតិ ការវិភាគស្ថិតិ ការផ្សព្វផ្សាយ និងការប្រើប្រាស់ស្ថិតិ ការប្រើប្រាស់ស្ថិតិតាមតំបន់ និងការប្រើប្រាស់លទ្ធផលអង្កេតស្ថិតិ។ លើសពីនេះទៀត ការបណ្តុះបណ្តាលតាមរយៈការងារជាច្រើនទៀតត្រូវបានផ្តល់ជូន។

វិទ្យាស្ថានជាតិស្ថិតិកំពុងចូលរួមក្នុងគម្រោងតំបន់ ដូចជាគម្រោងសាកល្បងរបស់ផ្នែកស្ថិតិសហប្រជាជាតិ អំពីការពង្រឹងការប្រមូល ភាពអាចរកបាន និងការផ្សព្វផ្សាយទិន្នន័យគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDG) និងគម្រោងសាកល្បងរបស់គណៈកម្មាធិការសេដ្ឋកិច្ច និងសង្គមកិច្ចរបស់អង្គការសហប្រជាជាតិ ដើម្បីអាស៊ីនិងប៉ាស៊ីហ្វិក (UNESCAP) អំពីការពង្រឹងការវាស់វែង និងស្ថិតិពិការភាព នៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក។

អង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) នៅកម្ពុជាបាន និងកំពុងគាំទ្រដល់សកម្មភាពទាក់ទងនឹងប្រជាជនរបស់វិទ្យាស្ថានជាតិស្ថិតិចាប់តាំងពីឆ្នាំ ១៩៩៥ មកដល់បច្ចុប្បន្ន។ ការអង្កេតប្រជាសាស្ត្រលើកទីមួយនៅឆ្នាំ ១៩៩៦ និងជំរឿនប្រជាជនលើកដំបូងនៅកម្ពុជាបន្ទាប់ពីរយៈពេល ៣៦ ឆ្នាំ ត្រូវបានដំណើរការនៅឆ្នាំ ១៩៩៨ ដោយមានការឧបត្ថម្ភពីអង្គការ UNFPA។ ការអង្កេតចន្លោះជំរឿនប្រជារាស្ត្រ ឆ្នាំ ២០០៤ (ICPS 2004) ក៏ត្រូវបានជួយឧបត្ថម្ភដោយអង្គការ UNFPA ផងដែរ។ នៅឆ្នាំ ២០០៦ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចចិត្តធ្វើជំរឿនប្រជារាស្ត្រ ឆ្នាំ ២០០៨។ អង្គការ UNFPA, JICA រាជរដ្ឋាភិបាលជប៉ុន និងរដ្ឋាភិបាលអាល្លឺម៉ង់ បានផ្តល់ជំនួយខាងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់សកម្មភាពផ្សេងៗដែលពាក់ព័ន្ធ។ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ត្រូវបានអនុវត្តនៅក្នុងឆ្នាំ ២០០០ និងឆ្នាំ ២០០៥ ហើយនៅឆ្នាំ ២០១០ ការអង្កេតត្រូវបានធ្វើឡើងដោយមានជំនួយពីអង្គការ USAID UNFPA UNICEF និងម្ចាស់ជំនួយមួយចំនួនផ្សេងទៀត។

អង្គការមូលនិធិកុមាររបស់អង្គការសហប្រជាជាតិ (UNICEF) កំពុងជួយដល់វិទ្យាស្ថានជាតិស្ថិតិជាមួយកម្មវិធី CAMInfo ប្រព័ន្ធទិន្នន័យមូលដ្ឋានសេដ្ឋកិច្ចសង្គមកិច្ច ដែលផ្តល់វេទិការទូទៅសម្រាប់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលដើម្បីរៀបចំ និងបង្ហាញទិន្នន័យអំពីសូចនាករអភិវឌ្ឍន៍។ សូចនាករបានបង្ហាញនៅក្នុងទិន្នន័យមូលដ្ឋានដែលទាក់ទងនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDGs) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ផែនការអប់រំ ផែនការសុខាភិបាល ផែនការវិនិយោគអាហារូបត្ថម្ភនៅកម្ពុជា និងផែនការផ្សេងៗទៀត។ទិន្នន័យមូលដ្ឋានអាចរកបាននៅវេបសាយវិទ្យាស្ថានជាតិស្ថិតិ។

### ១.៣ ការសម្របសម្រួលដោយកិច្ចសហប្រតិបត្តិការទូលំទូលាយ គឺជាមធ្យោបាយដ៏សំខាន់

តាមវិធីមួយចំនួន ការសម្របសម្រួលគឺជាលក្ខខណ្ឌចាំបាច់មួយសម្រាប់ការបង្កើតប្រព័ន្ធស្ថិតិជាតិប្រកបដោយនិរន្តរភាព និងផលិតស្ថិតិផ្លូវការប្រកបដោយគុណភាព។ កម្ពុជាបានជ្រើសរើសធ្វើការសម្របសម្រួលតាមរយៈកិច្ចសហប្រតិបត្តិការដ៏ទូលំទូលាយជាមួយគ្រប់អង្គភាព ស្ថិតិដែលបានចាត់តាំងទាំងអស់ដើម្បីឈានទៅដល់ប្រព័ន្ធស្ថិតិប្រកបដោយនិរន្តរភាព និងមានស្ថិតិផ្លូវការប្រកបដោយគុណភាព។ ការសម្របសម្រួលជាមួយអង្គភាពស្ថិតិដែលបានចាត់តាំងនឹងកាត់បន្ថយការចំណាយសម្រាប់ស្ថិតិផ្លូវការដែលបានចាត់តាំងក្នុងរយៈពេលយូរ និងបង្កើនគុណភាព និងភាពដែលអាចរកបាន។ បើស្ថិតិត្រូវបានប្រើប្រាស់ និងសរសើរដោយអ្នកប្រើប្រាស់ពួកគេនឹងកាន់តែគាំទ្រដល់ការផលិតស្ថិតិ។

ផ្អែកតាមច្បាប់ សេចក្តីលម្អិតត្រូវបានរៀបចំដោយវិទ្យាស្ថានជាតិស្ថិតិដោយសហការជាមួយអង្គភាពស្ថិតិដែលបានចាត់តាំងដែលជាអង្គភាពសំខាន់បំពេញមុខងារខុសៗគ្នា ក្នុងកិច្ចសហប្រតិបត្តិការទូលំទូលាយ។ ជាសរុប ការងារជាច្រើនសម្រាប់អង្គភាពស្ថិតិដែលបានចាត់តាំង ក៏ដូចជាសម្រាប់វិទ្យាស្ថានជាតិស្ថិតិដែលជាអង្គភាពដឹកនាំដ៏សំខាន់នៃការងារសម្របសម្រួល។ ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការរវាងអង្គភាពស្ថិតិដែលបានចាត់តាំង និងវិទ្យាស្ថានជាតិស្ថិតិ គឺជាមធ្យោបាយដ៏សំខាន់នៃការធានាផ្តល់ស្ថិតិប្រកបដោយគុណភាពសម្រាប់ការអភិវឌ្ឍន៍កម្ពុជា។

## ២ ច្បាប់ និងអនុក្រឹត្យ

ច្បាប់ស្តីពីស្ថិតិ គ្រប់គ្រងការងារទាំងឡាយដែលទាក់ទងដល់ការប្រមូល ការកែច្នៃ ការចងក្រង ការវិភាគ ការបោះពុម្ព និងការផ្សព្វផ្សាយទិន្នន័យស្ថិតិហើយមានវិសាលភាពគ្របដណ្តប់ទូទាំងព្រះរាជាណាចក្រកម្ពុជា។ នៅក្រោមច្បាប់មានអនុក្រឹត្យចំនួនពីរដែលកំណត់ការងារសម្រាប់ប្រព័ន្ធស្ថិតិជាតិ។ វិទ្យាស្ថានជាតិស្ថិតិមានអនុក្រឹត្យស្តីពីការរៀបចំរចនាសម្ព័ន្ធរបស់វិទ្យាស្ថានជាតិស្ថិតិដែលមិនបានពណ៌នាក្នុងរបាយការណ៍នេះ។

វាក្យស័ព្ទបច្ចេកទេសដែលប្រើក្នុងច្បាប់ត្រូវបានបង្ហាញក្នុងមាត្រា ២ នៃច្បាប់ស្តីពីស្ថិតិ និងក្នុងអនុក្រឹត្យស្តីពីការៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ។ វាក្យស័ព្ទមួយចំនួនត្រូវបានបង្ហាញក្នុងឯកសារទាំងពីរ។

### ២.១ ច្បាប់ស្តីពីស្ថិតិ

ក្រៅពីកំណត់ក្របខ័ណ្ឌសម្រាប់ការងារដែលច្បាប់ស្តីពីស្ថិតិគ្រប់គ្រង ច្បាប់ក៏ពណ៌នានូវវាក្យស័ព្ទបច្ចេកទេស គោលការណ៍ និងទិសដៅសម្រាប់អ្នកផលិតស្ថិតិផ្លូវការ ដែលបានចាត់តាំងផងដែរ។ ជំរឿនដែលត្រូវអនុវត្តក៏បានបង្ហាញផងដែរ។

ចំពោះការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការច្បាប់ស្តីពីស្ថិតិបានកំណត់ថា វិទ្យាស្ថានជាតិស្ថិតិក្រោមឱវាទក្រសួងផែនការ មានភារកិច្ចកសាងគោលនយោបាយស្ថិតិផ្លូវការក្នុងការបង្កើតប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយដែលគ្របដណ្តប់ស្ថិតិផ្លូវការដែលបានចាត់តាំងទាំងអស់ និងអង្គភាពស្ថិតិក្នុងក្រសួង ស្ថាប័ន។ រាជរដ្ឋាភិបាលត្រូវចេញអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការដែលបានចាត់តាំង។

ច្បាប់ស្តីពីស្ថិតិកំណត់ថាក្រុមប្រឹក្សាស្ថិតិត្រូវបានបង្កើតឡើង ដើម្បីផ្តល់ប្រឹក្សាជូនក្រសួងផែនការក្នុងការជំរុញកិច្ចអភិវឌ្ឍន៍ប្រព័ន្ធស្ថិតិជាតិ (មាត្រា ១៥) និងគណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវបានបង្កើតឡើងដើម្បីជួយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ក្នុងការសម្របសម្រួលផ្នែកបច្ចេកទេសស្ថិតិផ្លូវការរបស់រាជរដ្ឋាភិបាល (មាត្រា ១៦)។ សមាសភាព មុខងារ និងការងាររបស់គណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវបានកំណត់ដោយអនុក្រឹត្យ។

ទិន្នន័យស្ថិតិផលិតដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិត្រូវបានបោះពុម្ព និងផ្សព្វផ្សាយដល់អ្នកប្រើប្រាស់ទាំងអស់ (មាត្រា ១៩) ហើយរាល់ទិន្នន័យស្ថិតិដែលប្រកាសផ្សាយដោយ វិទ្យាស្ថានជាតិស្ថិតិ គឺជាស្ថិតិផ្លូវការដែលបានចាត់តាំង (មាត្រា ២០)។

ការសម្ងាត់របស់ទិន្នន័យត្រូវបានកំណត់ក្នុងមាត្រា ២២ ដែលចែងថា វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិត្រូវធានារក្សាការសម្ងាត់នូវរាល់ព័ត៌មានបុគ្គលទាំងឡាយ ដែលបានមកពីអ្នកឆ្លើយលើកលែងតែក្នុងករណីពិសេសដោយមានការឯកភាពពីអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ និងយល់ព្រមពីរដ្ឋមន្ត្រីក្រសួងផែនការ។ ទិន្នន័យតូចតាចអាចប្រកាសផ្សាយបាន បើអ្នកប្រើប្រាស់ធានាការសម្ងាត់របស់ទិន្នន័យ និងបើទិន្នន័យត្រូវបានប្រើសម្រាប់តែគោលបំណងស្ថិតិប៉ុណ្ណោះ។

## ២.២ អនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ

អនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ គ្រប់គ្រងរាល់ការងាររៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ កាតព្វកិច្ចស្ថិតិ និងការងារទាំងឡាយដើម្បីអនុវត្តច្បាប់ស្តីពីស្ថិតិនៃព្រះរាជាណាចក្រកម្ពុជា។

វិទ្យាស្ថានជាតិស្ថិតិ ជាស្ថាប័នសម្រាប់ធ្វើគោលនយោបាយស្ថិតិផ្លូវការរបស់រាជរដ្ឋាភិបាល ទទួលខុសត្រូវលើការបង្កើត និងដឹកនាំប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយដែលគ្របដណ្តប់ស្ថិតិផ្លូវការដែលបានចាត់តាំងទាំងអស់របស់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល និងអង្គភាពស្ថិតិខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីស្ថិតិនៅគ្រប់ឃុំ សង្កាត់។

រចនាសម្ព័ន្ធរបស់ប្រព័ន្ធស្ថិតិជាតិ រួមមានវិទ្យាស្ថានជាតិស្ថិតិ អង្គភាពស្ថិតិដែលបានចាត់តាំង និងមន្ត្រីធ្វើការក្នុងអង្គភាពទាំងនោះ។

ក្រុមប្រឹក្សាស្ថិតិមានតួនាទីផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងផែនការ ដែលទាក់ទងទៅនឹងការកំណត់គោលនយោបាយស្ថិតិផ្លូវការ និងតម្រូវការទាំងឡាយដែលត្រូវបានកំណត់ដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង។

ការបង្កើត និងទិសដៅរបស់ក្រុមប្រឹក្សាស្ថិតិត្រូវបានកំណត់នៅក្នុងអនុក្រឹត្យ ឧទាហរណ៍ សមាសភាព និងភាពទៀងទាត់នៃការប្រជុំរបស់ក្រុមប្រឹក្សាស្ថិតិ។ គណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវបានកំណត់តាមលក្ខខណ្ឌដូចគ្នាដោយអនុក្រឹត្យ។ សមាជិកក្រុមប្រឹក្សាស្ថិតិ និងសមាជិកគណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

គណៈកម្មាធិការសម្របសម្រួលស្ថិតិ មានភារកិច្ចជួយវិទ្យាស្ថានជាតិស្ថិតិក្នុងការងារពាក់ព័ន្ធនឹងការរៀបចំគោលនយោបាយស្ថិតិ នីតិវិធី និងបទប្បញ្ញត្តិសម្រាប់ប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការ។ គណៈកម្មាធិការសម្របសម្រួលស្ថិតិអាចបង្កើតក្រុមការងារបច្ចេកទេសស្ថិតិ ដើម្បីដោះស្រាយការងារបច្ចេកទេសស្ថិតិណាមួយដែលទាមទារការពិនិត្យ សិក្សា និងពិភាក្សាលម្អិត។

អនុក្រឹត្យក៏ចែងអំពីការសម្ងាត់នៃលទ្ធផលផងដែរ។ គ្មានលទ្ធផល ឬសម្រង់សង្ខេបត្រូវបានបោះពុម្ព ឬផ្សព្វផ្សាយតាមរបៀបដែលអាចនាំឲ្យស្គាល់អត្តសញ្ញាណរបស់បុគ្គល ឬអង្គភាពណាមួយឡើយ។

ការងារដែលបានកំណត់ក្នុងអនុក្រឹត្យ សម្រាប់វិទ្យាស្ថានជាតិស្ថិតិ និងអ្នកផលិតស្ថិតិផ្លូវការដែលបានចាត់តាំងត្រូវបានពណ៌នាក្នុងផ្នែក ៣.៥ និង ៣.៦។

## ២.៣ អនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង

អនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង មានគោលដៅកំណត់ឲ្យក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ប្រមូល និងចងក្រងស្ថិតិផ្លូវការដែលបានចាត់តាំងទៅតាមវិស័យរបស់ខ្លួន (មាត្រា ១) និងគ្រប់គ្រងរាល់ស្ថិតិផ្លូវការដែលបានចាត់តាំង និងអង្គភាពស្ថិតិដែលបានចាត់តាំងដូចមានចែងក្នុងច្បាប់ស្តីពីស្ថិតិ។

អនុក្រឹត្យមានគោលបំណងបម្រើសំណូមពរព័ត៌មានស្ថិតិរបស់អ្នកធ្វើគោលនយោបាយ ក្នុងការរៀបចំវាយតម្លៃលើគោលនយោបាយ និងកម្មវិធីសេដ្ឋកិច្ច សង្គមកិច្ច ដើម្បីឆ្លើយតបនឹងកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់ប្រទេស ក៏ដូចជាបម្រើសេចក្តីត្រូវការព័ត៌មានរបស់អ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិ និងអន្តរជាតិដ៏ទូលំទូលាយ។

គ្រប់ទិន្នន័យស្ថិតិទាំងអស់ដែលបានប្រកាសផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ គឺជាស្ថិតិផ្លូវការដែលបានចាត់តាំង។ វិទ្យាស្ថានជាតិស្ថិតិត្រូវប្រកាសផ្សាយដល់សាធារណជននូវស្ថិតិគ្រឹះ និងស្ថិតិតាមវិស័យ ទោះបីផលិតដោយខ្លួនឯង ឬដោយសហការជាមួយអង្គភាពស្ថិតិផ្សេងទៀតរបស់រាជរដ្ឋាភិបាល ៖

- ស្ថិតិជំរឿន
- ស្ថិតិអង្កេត
- ស្ថិតិសេដ្ឋកិច្ច
- ស្ថិតិបរិស្ថាន និងធនធានធម្មជាតិ
- ស្ថិតិសង្គមកិច្ច ប្រជាសាស្ត្រ
- កម្រងស្ថិតិ

អនុក្រឹត្យបានកំណត់ថា អង្គភាពស្ថិតិត្រូវទទួលខុសត្រូវលើការអង្កេត។ ចំនួនទាំងអស់មាន ២៧ ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ ដោយរាប់បញ្ចូលទាំងធនាគារជាតិនៃកម្ពុជា មានភារកិច្ចទទួលខុសត្រូវលើស្ថិតិផ្លូវការដែលបានចាត់តាំង ក្រៅពីស្ថិតិដែលផលិតដោយវិទ្យាស្ថានជាតិស្ថិតិ។

ក្នុងជំពូក ៤ នៃអនុក្រឹត្យ ការគ្រប់គ្រងទិន្នន័យ និងប្រភពប្រមូលទិន្នន័យត្រូវបានកំណត់។ មាត្រា ៨ ចែងថា រាល់ការប្រមូលទិន្នន័យដែលមានស្រាប់ ត្រូវចុះបញ្ជីនៅវិទ្យាស្ថានជាតិស្ថិតិ។ ការប្រមូលទិន្នន័យដែលបានគ្រោងទុក និងថ្មីក៏ត្រូវចុះបញ្ជីផងដែរ មុននឹងចាប់ផ្តើមអនុវត្តការងារ។

បញ្ជីនៃរាល់ការប្រមូលទិន្នន័យដែលមានស្រាប់ ការចំណាយ និងស្ថានភាពនៃការប្រមូលទិន្នន័យនីមួយៗ ត្រូវបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីនៅឆ្នាំដំបូង បន្ទាប់ពីអនុក្រឹត្យចូលជាធរមាន។ បញ្ជីត្រូវធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ (មាត្រា ១០)។

អង្គភាពស្ថិតិដែលបានចាត់តាំងនៅតាមក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ត្រូវបញ្ជូននូវរាល់ព័ត៌មាន និងទិន្នន័យស្ថិតិដែលផលិតបានជាទម្រង់អេឡិចត្រូនិច និងជាសៀវភៅទៅវិទ្យាស្ថានជាតិស្ថិតិ និងទៅទីស្តីការគណៈរដ្ឋមន្ត្រីឲ្យបានទៀងទាត់ និងទាន់ពេលវេលា (មាត្រា ១១)។

វិទ្យាស្ថានជាតិស្ថិតិត្រូវបង្កើត និងថែរក្សាទុកនូវបញ្ជីឈ្មោះប្រភពទិន្នន័យរដ្ឋបាល និងស្ថិតិដោយផ្អែកលើការប្រមូលព័ត៌មានម៉េតាទិន្នន័យតាមរយៈដំណើរការចុះបញ្ជី។
បញ្ជីឈ្មោះម៉េតាទិន្នន័យត្រូវធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ និងប្រកាសផ្សាយតាមវេបសាយរបស់វិទ្យាស្ថានជាតិស្ថិតិ (មាត្រា ១២)។

# ៣ រចនាសម្ព័ន្ធនៃប្រព័ន្ធស្ថិតិជាតិ

## ៣.១ និយមន័យនៃស្ថិតិផ្លូវការដែលបានចាត់តាំង

និយមន័យនៃស្ថិតិផ្លូវការដែលបានចាត់តាំងយោងតាមចំណុចទី ១០ មាត្រា ២ ក្នុងច្បាប់ស្តីពីស្ថិតិ "ស្ថិតិផ្លូវការដែលបានចាត់តាំង គឺជាស្ថិតិដែលបានផលិតដោយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល

ដែលកំណត់ដោយរាជរដ្ឋាភិបាល ដើម្បីបម្រើសំណូមពរព័ត៌មានស្ថិតិរបស់អ្នកធ្វើគោលនយោបាយ ក៏ដូចជាតម្រូវការរបស់អ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកស្រាវជ្រាវ"។

## ៣.២ លក្ខណៈទូទៅនៃប្រព័ន្ធស្ថិតិជាតិ

ប្រព័ន្ធស្ថិតិជាតិនៅកម្ពុជាមានលក្ខណៈវិមជ្ឈការខ្ពស់។ ស្ថាប័នកណ្តាលក្នុងប្រព័ន្ធស្ថិតិជាតិ គឺវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។ យោងតាមច្បាប់ស្តីពីស្ថិតិ វិទ្យាស្ថានជាតិស្ថិតិជាស្ថាប័នស្ថិតិជាតិផ្លូវការរបស់រាជរដ្ឋាភិបាល ដែលមានភារកិច្ចទទួលខុសត្រូវលើការបង្កើត និងដឹកនាំប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយ ដែលគ្របដណ្តប់ស្ថិតិផ្លូវការដែលបានចាត់តាំងទាំងអស់ និងអង្គភាពស្ថិតិក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។ បន្ថែមពីលើវិទ្យាស្ថានជាតិស្ថិតិ ក្រសួងនីមួយៗ និងស្ថាប័នរាជរដ្ឋាភិបាលដទៃទៀតត្រូវមានអង្គភាពស្ថិតិទទួលខុសត្រូវលើការផលិតស្ថិតិ។ ក្រសួងនីមួយៗ និងស្ថាប័ននានាត្រូវប្រមូល និងផលិតស្ថិតិដែលជាផ្នែកនៃការងាររបស់ពួកគេ។ ប្រព័ន្ធរួមមាន វិទ្យាស្ថានជាតិស្ថិតិ និង ២៧ ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជា ដែលជាសមាជិកគណៈកម្មាធិការសម្របសម្រួលស្ថិតិ និងអ្នកផលិត ឬអ្នកប្រើប្រាស់ស្ថិតិផ្លូវការដែលបានចាត់តាំង។

តាមច្បាប់ស្តីពីស្ថិតិ វិទ្យាស្ថានជាតិស្ថិតិមានភារកិច្ច ៖

១. ធ្វើការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការក្នុងសកម្មភាពនៃកិច្ចអភិវឌ្ឍន៍ស្ថិតិ រួមនឹងការបណ្តុះបណ្តាលជាមួយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ក៏ដូចជាវិស័យឯកជន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
២. ធ្វើកិច្ចសហប្រតិបត្តិការក្នុងសកម្មភាពស្ថិតិ ជាមួយអង្គការអន្តរជាតិ អង្គភាពស្ថិតិជាតិនៃប្រទេសនានា និងផ្នែកឯកជននានា
៣. កំណត់ស្តង់ដារស្ថិតិជាតិ ដែលទាក់ទងនឹងចំណាត់ថ្នាក់ ទស្សនទាន និយមន័យ និងអង្គពិនិត្យពិចារណាស្ថិតិ។

វិទ្យាស្ថានជាតិស្ថិតិក៏ទទួលខុសត្រូវលើការរក្សាទុក ការធ្វើបច្ចុប្បន្នកម្ម និងការអនុវត្តន៍កម្មវិធីស្ថិតិសម្រាប់រាជរដ្ឋាភិបាល និងផ្តល់ទិន្នន័យដល់អ្នកប្រើប្រាស់នានាក្នុងប្រទេសក៏ដូចជាអង្គការអន្តរជាតិ។

យោងតាមអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ ក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវបានបង្កើតឡើងនៅខែ មករា ឆ្នាំ ២០០៧ ដើម្បីជួយដល់វិទ្យាស្ថានជាតិស្ថិតិក្នុងការសម្របសម្រួលផ្នែកបច្ចេកទេសនៃស្ថិតិផ្លូវការ។

## ៣.៣ ភារៈនិងសមាសភាពក្រុមប្រឹក្សាស្ថិតិ

ការបង្កើតក្រុមប្រឹក្សាស្ថិតិ ត្រូវបានចែងក្នុងច្បាប់ស្ដីពីស្ថិតិ។ ក្រុមប្រឹក្សាស្ថិតិរួមមាន ក្រសួងផែនការ (ប្រធាន) រដ្ឋលេខាធិការក្រសួងផែនការ ទទួលខុសត្រូវលើស្ថិតិផ្លូវការ (អនុប្រធាន) និងរដ្ឋលេខាធិការដែលជាតំណាងមកពីក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ទទួលបន្ទុកលើគោលនយោបាយសេដ្ឋកិច្ច និងសង្គមកិច្ចសំខាន់ៗ ដូចជា ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងសុខាភិបាល ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងទេសចរណ៍ ក្រសួងកិច្ចការនារី ធនាគារជាតិនៃកម្ពុជា (អនុប្រធាន) និងតំណាងម្នាក់នៃមជ្ឈដ្ឋានឧត្ដមសិក្សា។ អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិមានតួនាទីជាសមាជិកអចិន្ត្រៃយ៍។ សមាជិកទាំងអស់មានចំនួន ១៩ នាក់ តំណាងឲ្យក្រុមប្រឹក្សាស្ថិតិ។

ក្រុមប្រឹក្សាស្ថិតិ មានតួនាទីផ្ដល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងផែនការ ដែលទាក់ទងទៅនឹង ៖

- ការកំណត់គោលនយោបាយស្ថិតិផ្លូវការ
- តម្រូវការស្ថិតិផ្លូវការ និងការផ្ដល់អាទិភាពដល់គម្រោងការងារស្ថិតិ ដែលស្នើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលចាត់តាំង
- ការធ្វើឲ្យប្រសើរឡើង ការពង្រីក និងការសម្របសម្រួលនូវប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការដែលបានចាត់តាំង សម្រាប់គោលបំណងសាធារណៈ
- ការធ្វើវិសោធនកម្មណាមួយទៅលើច្បាប់ស្ដីពីស្ថិតិ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធការងារស្ថិតិ
- កម្មវិធីការងារស្ថិតិអាទិភាពរយៈពេល ១ ឆ្នាំ រយៈពេលមធ្យម និងរយៈពេលវែងរបស់វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំងដែលទាក់ទងក្នុងការផលិតស្ថិតិផ្លូវការ
- ផែនការមេស្ថិតិ
- ការកំណត់កាលបរិច្ឆេទ នៃការធ្វើជំរឿនប្រជាពលរដ្ឋ កសិកម្ម និងសហគ្រាស
- ការងារផ្សេងៗ ដែលទាក់ទងជាទូទៅនឹងប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការ
- ការស្វែងរកជំនួយ និងការគាំទ្រ ធនធានហិរញ្ញវត្ថុ និងធនធានមនុស្សដែលត្រូវការដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង ដើម្បីធ្វើជំរឿន អង្កេត ផលិត និងផ្សព្វផ្សាយស្ថិតិផ្លូវការសម្រាប់គោលបំណងសាធារណៈ។

ក្រុមប្រឹក្សាស្ថិតិបានប្រជុំលើកដំបូងរបស់ខ្លួននៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៧។ អង្គប្រជុំបានពិភាក្សាអំពីការរៀបចំផែនការមេស្ថិតិសម្រាប់ប្រទេសកម្ពុជា ដើម្បីកំណត់ផែនការអាទិភាពរយៈពេលវែងនៃការងារស្ថិតិ បង្កើតក្របខ័ណ្ឌ និងធនធានហិរញ្ញវត្ថុ សម្រាប់ដំណើរការប្រព័ន្ធស្ថិតិប្រកបដោយប្រសិទ្ធភាព។ ផែនការមេស្ថិតិនេះ ត្រូវឆ្លងកាត់សមាជិកក្រុមប្រឹក្សាស្ថិតិជាមុនសិន មុននឹងបញ្ជូនទៅទីស្ដីការគណៈរដ្ឋមន្ត្រីសុំការយល់ព្រម។ កិច្ចប្រជុំក្រុមប្រឹក្សាស្ថិតិ លើសេចក្ដីព្រៀងផែនការមេស្ថិតិត្រូវបានយល់ព្រម។

## ៣.៤ ភារៈការ និងសមាសភាពគណៈកម្មាធិការសម្របសម្រួលស្ថិតិ

ការបង្កើតគណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវបានចែងក្នុងច្បាប់ស្ដីពីស្ថិតិ។ គណៈកម្មាធិការសម្របសម្រួលស្ថិតិ រួមមានអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ (ប្រធាន) អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ (អនុប្រធាន) ប្រធាននាយកដ្ឋានគោលនយោបាយ និងសហប្រតិបត្តិការស្ថិតិ នៃវិទ្យាស្ថានជាតិស្ថិតិ (លេខាធិការ) និងប្រធានអង្គភាពស្ថិតិនីមួយៗ ក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលនីមួយៗជាសមាជិក ដែលមានសមាជិកទាំងអស់ចំនួន ៣២ នាក់។

គណៈកម្មាធិការសម្របសម្រួលស្ថិតិ មានភារកិច្ចជួយវិទ្យាស្ថានជាតិស្ថិតិ ក្នុងការងារពាក់ព័ន្ធទៅនឹង ៖

- ការកសាងគោលនយោបាយស្ថិតិ នីតិវិធី និងបទប្បញ្ញត្តិ ដែលទាក់ទងនឹងប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការ
- ការធ្វើសមាហរណកម្មប្រព័ន្ធស្ថិតិជាតិមួយ តាមរយៈការសម្របសម្រួល និងសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពលើសកម្មភាព និងការអភិវឌ្ឍស្ថិតិរវាងអង្គភាពស្ថិតិដែលបានចាត់តាំងរួមទាំងវិទ្យាស្ថានជាតិស្ថិតិ ដើម្បីទទួលខុសត្រូវ ក្នុងការផលិត និងការផ្សព្វផ្សាយស្ថិតិផ្លូវការ
- ការធ្វើឲ្យប្រសើរឡើង និងការពង្រីកប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការដែលផ្ដល់សម្រាប់គោលដៅសាធារណៈ
- ការលើកអាទិភាពនៃកម្មវិធីការងារប្រចាំឆ្នាំ រយៈពេលមធ្យម និងរយៈពេលវែង ដែលគួរត្រូវបានជ្រើសរើសទាក់ទងនឹងទិដ្ឋភាពសំខាន់ៗនៃការផ្ដល់ស្ថិតិផ្លូវការ ដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង
- ការរៀបចំ និងធ្វើបច្ចុប្បន្នកម្មផែនការមេស្ថិតិ
- ការៀបចំផែនការធ្វើជំរឿនប្រជារាស្ត្រ កសិកម្ម និងសហគ្រាស
- ការបង្កើតនូវបញ្ជីពាណិជ្ជកម្ម ឬក្របខ័ណ្ឌសរុប បញ្ជីឈ្មោះប្រភពទិន្នន័យរដ្ឋបាល និងស្ថិតិដែលទាក់ទងនឹងប្រព័ន្ធស្ថិតិជាតិ ព្រមទាំងថែរក្សាដោយប្រសិទ្ធភាព និងធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំ

- កិច្ចព្រមព្រៀងសហប្រតិបត្តិការ និងកិច្ចសម្របសម្រួល រវាងបណ្តាក្រសួង ស្ថាប័ន និងបណ្តាអង្គភាពរាជរដ្ឋាភិបាល អំពីការផ្លាស់ប្តូរទិន្នន័យ និងការផ្តល់ទាន់ពេលវេលានូវស្ថិតិផ្លូវការឲ្យបានទៀងទាត់ និងគួរជឿទុកចិត្តបាន
- ការបង្កើតក្រុមការងារបច្ចេកទេសស្ថិតិ រយៈពេលកំណត់ ឬអចិន្ត្រៃយ៍ សម្រាប់ស្ថិតិណាមួយ ឬការងារស្ថិតិផ្សេងទៀត ដែលទាក់ទងនឹងប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការ
- ការប្រកាសឲ្យប្រើ និងការអនុវត្តនូវចំណាត់ថ្នាក់ និងបទដ្ឋានស្ថិតិ ដែលទាក់ទងនឹងស្ថិតិផ្លូវការ
- ការលើកផែនការថវិកា និងធនធានមនុស្ស សម្រាប់អង្គភាពស្ថិតិដែលបានចាត់តាំង រួមទាំងវិទ្យាស្ថានជាតិស្ថិតិ ដើម្បីដឹកនាំការធ្វើជំរឿន និងអង្កេត ផលិត និងផ្សព្វផ្សាយស្ថិតិផ្លូវការសម្រាប់គោលដៅសាធារណៈ។

### ៣.៤.១ ការប្រជុំគណៈកម្មាធិការ

រហូតមកដល់ពេលនេះ ការប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិមានចំនួន ៧ លើក ហើយ។ ដោយសារតែនេះជារបាយការណ៍ប្រចាំឆ្នាំលើកដំបូង រាល់ការប្រជុំត្រូវបានលើកមកបង្ហាញ។ ចាប់ពីរបាយការណ៍សម្រាប់ឆ្នាំបន្ទាប់ មានតែការប្រជុំគណៈកម្មាធិការនៅឆ្នាំមុនប៉ុណ្ណោះ ដែលត្រូវបានពណ៌នា។

ការប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិលើកដំបូង ត្រូវបានធ្វើឡើងនៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០៧។ អង្គប្រជុំបានពិភាក្សាអំពីការរៀបចំផែនការមេស្ថិតិ។ ផែនការមេស្ថិតិដែលបានផលិតនៅខែមេសា ឆ្នាំ២០០៦ ត្រូវបានធ្វើបច្ចុប្បន្នកម្មលើកាលបរិច្ឆេទ និងការចំណាយ។ ផែនការមេស្ថិតិត្រូវបានបញ្ជូនទៅក្រុមប្រឹក្សាស្ថិតិ ដើម្បីសុំការយល់ព្រម។ នេះជាដំណើរការដ៏មានសារៈសំខាន់មួយក្នុងការជួយគាំទ្រសម្រាប់ការគាំទ្ររបស់រាជរដ្ឋាភិបាល និងធនធាន ដើម្បីធានាឲ្យការងារសម្របសម្រួលស្ថិតិមានប្រសិទ្ធភាព។ ផែនការមេស្ថិតិបានព្យាយាមធានាថា ថវិកាមានគ្រប់គ្រាន់សម្រាប់គុណភាពស្ថិតិ ដែលផលិតដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិក្នុងក្រសួង ស្ថាប័នពាក់ព័ន្ធ។

ការប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិលើកទី ២ នាថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៧ បានពិភាក្សាអំពីការរៀបចំសេចក្តីព្រៀងអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង ដែលតម្រូវឲ្យក្រសួង ស្ថាប័នពាក់ព័ន្ធធ្វើការចងក្រង និងផ្ញើព័ត៌មានតាមសន្និធិស្ថិតិដែលផលិតជាទៀងទាត់។ នាឱកាសនោះ អង្គប្រជុំបានស្នើសុំយោបល់ពីក្រសួង ស្ថាប័ន អំពីបញ្ជីស្ថិតិផ្លូវការដែលបានស្នើឡើង។

ការប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិលើកទី ៣ ត្រូវបានធ្វើឡើងនៅថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០០៨។ ការប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិលើកនេះត្រូវបានពន្យារពេលដោយសារ

ព្រឹត្តិការណ៍មួយចំនួន ដូចជាការបោះឆ្នោតទូទៅ ការធ្វើជំរឿនប្រជារាស្ត្រទូទៅនៅប្រទេសកម្ពុជា ដូច្នេះគណៈកម្មាធិការសម្របសម្រួលស្ថិតិបានជួបប្រជុំតែម្តងប៉ុណ្ណោះ ក្នុងមួយឆ្នាំ ២០០៨។ អង្គប្រជុំបន្តត្រួតពិនិត្យសេចក្តីព្រៀងអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង ដោយស្នើឲ្យក្រសួង ស្ថាប័នពាក់ព័ន្ធបន្ថែមស្ថិតិសំខាន់ៗ មួយចំនួន និង/ឬកាត់ចោលស្ថិតិដែលមិនចាំបាច់។

នៅថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០០៩ ការប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិលើកទី ៤ ត្រូវបានធ្វើឡើង។ ការប្រជុំនេះមានបំណងប្រមូលយោបល់ និងអនុសាសន៍ទាំងឡាយរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើបច្ចុប្បន្នកម្ម សេចក្តីព្រាងអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង។ ក្នុងពេលនោះដែរ គម្រោង Sida បានធ្វើបទបង្ហាញអំពីបទពិសោធន៍ និងការបង្កើតស្ថិតិផ្លូវការនៅប្រទេសស៊ុយអែត។

ការប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិលើកទី ៥ នាថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ សេចក្តីព្រាងអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំងត្រូវបានបញ្ចប់។ ប្រធានក្រុមទីប្រឹក្សាគម្រោង Sida ត្រូវបានអញ្ជើញឲ្យធ្វើបទបង្ហាញអំពីសកម្មភាពចាំបាច់មួយចំនួន ដែលទាក់ទងនឹងការរៀបចំអនុក្រឹត្យឲ្យមានប្រសិទ្ធភាព។ រវាងការប្រជុំទី ៤ និងទី៥ វិទ្យាស្ថានជាតិស្ថិតិបានសម្រេចបានអនុក្រឹត្យសំខាន់ៗ ចំនួន ២ គឺអនុក្រឹត្យស្តីពីការបង្កើតនាយកដ្ឋានមួយចំនួន ចំណុះវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងអនុក្រឹត្យស្តីពីជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១១ និងមានព្រឹត្តិការណ៍ធំមួយនៃការប្រកាសផ្សាយលទ្ធផលចុងក្រោយ នៃជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ ២០០៨។

ការប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិលើកទី ៦ នាថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ២០១០ បានរាយការណ៍អំពីសកម្មភាពរបស់វិទ្យាស្ថានជាតិស្ថិតិ ក្នុងការរៀបចំអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំងការងារដែលបានអនុវត្តដោយក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល បន្ទាប់ពីអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំងត្រូវបានអនុម័ត។ ការងាររបស់អាស៊ានក៏ត្រូវបានពិភាក្សាផងដែរក្នុងអង្គប្រជុំដែលទាក់ទងនឹងការផ្លាស់ប្តូរព័ត៌មានស្ថិតិ ក្នុងគ្រប់វិស័យប្រកបដោយភាពអាចទុកចិត្តបានភាពទាន់ពេលវេលា និងភាពអាចប្រៀបធៀបបានក្នុងប្រព័ន្ធស្ថិតិអាស៊ាន។ អង្គប្រជុំបានព្រមព្រៀងពង្រឹងក្របខ័ណ្ឌនៃប្រព័ន្ធស្ថិតិសហគមន៍អាស៊ាន ដល់ឆ្នាំ ២០១៥។

ការប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិលើកទី ៧ បានធ្វើឡើងនៅថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១០។ អង្គប្រជុំបានបង្ហាញអំពីការចាំបាច់នៃការសម្របសម្រួល និងវិធីសាស្ត្រដែលប្រតិបត្តិក្នុងប្រព័ន្ធស្ថិតិ។ អង្គប្រជុំក៏បានធ្វើការរំលឹកដល់សមាជិកគណៈកម្មាធិការ ឲ្យប្រគល់បញ្ជីសំណួរដែលបំពេញហើយនៃការអង្កេតសន្និធិស្ថិតិផ្លូវការមកវិទ្យាស្ថានជាតិស្ថិតិ។ ក្នុងឱកាសនោះបញ្ជីសំណួរនៃម៉េតាទិន្នន័យស្ថិតិផ្លូវការដែលបានចាត់តាំង ក៏ត្រូវបានធ្វើបទបង្ហាញ និងពន្យល់ផងដែរអំពីការណែនាំរបៀបបំពេញ។

## ៣.៥ ការងារសម្របសម្រួលសម្រាប់វិទ្យាស្ថានជាតិស្ថិតិ យោងតាមច្បាប់

ច្បាប់ស្តីពីស្ថិតិបានផ្តល់ការងារដល់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីទទួលខុសត្រូវលើការសម្របសម្រួលក្នុងសកម្មភាពអភិវឌ្ឍន៍ រួមទាំងការបណ្តុះបណ្តាលជាមួយក្រសួង និងស្ថាប័នរបស់រាជរដ្ឋាភិបាល និងផ្នែកឯកជននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

របាយការណ៍ប្រចាំឆ្នាំនេះ និងបញ្ជីឈ្មោះស្ថិតិផ្លូវការដែលបានចាត់តាំង គឺជាការងារដែលវិទ្យាស្ថានជាតិស្ថិតិត្រូវការបញ្ចប់ក្នុងរយៈពេល ១ ឆ្នាំ បន្ទាប់ពីអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំងចូលជាធរមាន។

យោងតាមអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ មាត្រា ៦ វិទ្យាស្ថានជាតិស្ថិតិជាស្ថាប័នស្ថិតិជាតិផ្លូវការរបស់រាជរដ្ឋាភិបាល មានភារកិច្ចទទួលខុសត្រូវធានាការសម្របសម្រួល ប្រតិបត្តិការរបស់អង្គភាពស្ថិតិដែលបានចាត់តាំងក្នុងការប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព ផ្សព្វផ្សាយស្ថិតិផ្លូវការ និងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិដើម្បី ៖

- ចៀសវាងនូវការជាន់ភារកិច្ចគ្នា ក្នុងការប្រមូលព័ត៌មានសម្រាប់គោលបំណងស្ថិតិផ្លូវការដោយអង្គភាពស្ថិតិដែលបានចាត់តាំង
- ទទួលបាននូវភាពត្រូវគ្នា និងការរួមបញ្ចូលគ្នារវាងស្ថិតិផ្លូវការទាំងឡាយដែលចងក្រងដោយអង្គភាពស្ថិតិដែលបានចាត់តាំង
- ធ្វើឲ្យមានប្រសិទ្ធភាពដល់កិច្ចអភិវឌ្ឍន៍ ការរៀបចំជាឯកសារ និងការផ្សព្វផ្សាយអំពីទស្សនៈ ប្រភព និងវិធីសាស្ត្រស្ថិតិ
- អនុវត្តគោលនយោបាយស្ថិតិ ដែលមានរួមបញ្ចូលនូវគោលនយោបាយទាក់ទងនឹងការផ្សព្វផ្សាយស្ថិតិផ្លូវការ និងប្រតិទិនប្រកាសផ្សាយជាមុន នូវការផ្សព្វផ្សាយស្ថិតិផ្លូវការ និង
- បង្កើនលទ្ធភាពប្រើប្រាស់ជាអតិបរមានូវព័ត៌មាន និងមធ្យោបាយនៃការប្រមូល និងផ្សព្វផ្សាយព័ត៌មាន ដែលមាននៅតាមអង្គភាពស្ថិតិដែលបានចាត់តាំង។

វិទ្យាស្ថានជាតិស្ថិតិសហការជាមួយអង្គភាពស្ថិតិដែលបានចាត់តាំងរបស់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលក៏ដូចជាអាជ្ញាធរខេត្ត ស្រុក ខណ្ឌ ឃុំ សង្កាត់ក្នុងការប្រមូល ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយស្ថិតិរួមទាំងស្ថិតិដែលទទួលបានពីកំណត់ត្រារដ្ឋបាល ក្នុងគោលបំណងសម្របសម្រួលសកម្មភាពស្ថិតិ និងធានាការប្រតិបត្តិបទដ្ឋានស្ថិតិ។

យោងតាមអនុក្រឹត្យស្តីពីការបង្កើតនាយកដ្ឋានថ្មី នៃវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ នាយកដ្ឋានស្តង់ដារស្ថិតិ និងវិភាគស្ថិតិត្រូវបានបង្កើតឡើង និងផ្តល់ការទទួលខុសត្រូវក្នុងការសម្របសម្រួលការអនុវត្តន៍ស្តង់ដារស្ថិតិ និងចំណាត់ថ្នាក់ស្ថិតិ និយមន័យស្ថិតិ និងវិធីសាស្ត្រស្ថិតិសម្រាប់អនុវត្តដោយអង្គភាពស្ថិតិដែលបានចាត់តាំង។

បន្ថែមពីនេះទៀត នាយកដ្ឋាននេះក៏បានបង្កើតការិយាល័យសម្របសម្រួលស្ថិតិផងដែរ ដែលមានភារកិច្ចដូចខាងក្រោម ៖

- សម្របសម្រួលក្នុងការអនុវត្តចំណាត់ថ្នាក់ស្តង់ដារស្ថិតិ និយមន័យស្ថិតិ និងវិធីសាស្ត្រស្ថិតិ ជាមួយអង្គភាពស្ថិតិនៃក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល
- ចងក្រងបញ្ជីឈ្មោះទិន្នន័យស្ថិតិរដ្ឋបាល ជំរឿន និងអង្កេតដែលមានស្រាប់របស់វិទ្យាស្ថានជាតិស្ថិតិ និងក្រសួង ស្ថាប័នរាជរដ្ឋាភិបាល
- ចុះបញ្ជីឈ្មោះរាល់ទិន្នន័យស្ថិតិរដ្ឋបាល ជំរឿន និងអង្កេតថ្មី ដែលបានគ្រោងទុករបស់វិទ្យាស្ថានជាតិស្ថិតិ និងក្រសួង ស្ថាប័នរាជរដ្ឋាភិបាល
- ផ្តល់ប្រឹក្សាស្ថិតិក្នុងការប្រមូលទិន្នន័យរដ្ឋបាល ជំរឿន និងអង្កេតរបស់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល
- សម្របសម្រួលក្នុងការប្រមូលទិន្នន័យស្ថិតិផ្លូវការ និងទិន្នន័យចាំបាច់ពីក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល
- សម្របសម្រួលការងារស្ថិតិជាមួយក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។

ភារកិច្ចសម្រាប់វិទ្យាស្ថានជាតិស្ថិតិមានជាច្រើន ប្រហាក់ប្រហែលនឹងអង្គភាពស្ថិតិដែលបានចាត់តាំងផ្សេងៗ ដោយសារតែការទទួលខុសត្រូវកិច្ចសម្របសម្រួលរបស់វិទ្យាស្ថានជាតិស្ថិតិ។ ការងារ សម្របសម្រួលសម្រាប់វិទ្យាស្ថានជាតិស្ថិតិ គឺ ៖

- ធ្វើគោលនយោបាយស្ថិតិផ្លូវការ
- រៀបចំច្បាប់ពាក់ព័ន្ធនឹងស្ថិតិ
- រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការមេសម្រាប់ស្ថិតិ
- ធ្វើការងារសម្រាប់ការយល់ដឹងជាសាធារណៈអំពីសារៈសំខាន់នៃស្ថិតិ
- ផ្តល់ទំនាក់ទំនងជាមួយប្រទេស និងអង្គការអន្តរជាតិនានា
- ធ្វើជាប្រធានគណៈកម្មាធិការសម្របសម្រួលស្ថិតិ
- ដឹកនាំការសម្របសម្រួលក្នុងការគាំទ្រដល់មាតិកា ការប្រមូល ការចងក្រង ការវិភាគ និងការផ្សព្វផ្សាយ
- ដឹកនាំសហប្រតិបត្តិការ
- សម្របសម្រួល និងដឹកនាំការអភិវឌ្ឍន៍របស់ប្រព័ន្ធស្ថិតិជាតិប្រកបដោយប្រសិទ្ធភាព និងសមត្ថភាព
- រៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីសកម្មភាពស្ថិតិរបស់ប្រព័ន្ធស្ថិតិជាតិ
- រក្សាទុកបញ្ជីពាណិជ្ជកម្ម និងក្របខ័ណ្ឌប្រជាជន
- រក្សាទុកបញ្ជីឈ្មោះប្រភពទិន្នន័យរដ្ឋបាល និងទិន្នន័យស្ថិតិ
- ប្រើប្រាស់ជាអតិបរមានូវព័ត៌មានដែលបានពីអង្គភាពស្ថិតិដែលបានចាត់តាំង

- សហការជាមួយ និងផ្តល់ប្រឹក្សា និងជួយដល់អង្គភាពស្ថិតិដែលបានចាត់តាំង
- រៀបចំតារាងគំរូដែលត្រូវការ
- ដឹកនាំបង្កើតស្តង់ដារ និងទស្សនទានស្ថិតិ
- ដឹកនាំបង្កើតវិធីសាស្ត្រស្ថិតិ
- ដឹកនាំការបណ្តុះបណ្តាលមន្ត្រីស្ថិតិ

## ៣.៦ ភារៈការសម្រាប់អង្គភាពស្ថិតិដែលបានចាត់តាំង

យោងតាមអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ មាត្រា ៦ អង្គភាពស្ថិតិដែលបានចាត់តាំង ជាអង្គភាពស្ថិតិកណ្តាលរបស់ក្រសួង ឬស្ថាប័នរាជរដ្ឋាភិបាលមានភារកិច្ចទទួលខុសត្រូវដូចតទៅ ៖

- ប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយស្ថិតិផ្លូវការ និងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ។
- បញ្ជូនស្ថិតិដែលបានផលិត និងផ្តល់ឯកសារ វិធីសាស្ត្រដែលទាក់ទងដល់វិទ្យាស្ថានជាតិស្ថិតិជាទម្រង់អេឡិចត្រូនិច និងឯកសារជាក្រដាស។
- សហប្រតិបត្តិការជាមួយវិទ្យាស្ថានជាតិស្ថិតិ ក្នុងការប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយស្ថិតិផ្លូវការ និងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិដើម្បី ៖
  - ចៀសវាងនូវការជាន់គ្នា ក្នុងសកម្មភាពស្ថិតិ និងស្ថិតិផ្លូវការ
  - បន្ថយមកត្រឹមកម្រិតអប្បបរមានូវបន្ទុកអ្នកឆ្លើយ
  - ទទួលបាននូវការឯកភាពគ្នា និងការរួមបញ្ចូលគ្នា រវាងស្ថិតិផ្លូវការទាំងឡាយ និង
  - អនុវត្តគោលនយោបាយ និងបទដ្ឋានស្ថិតិ ដែលប្រកាសឲ្យប្រើដោយវិទ្យាស្ថានជាតិស្ថិតិ។

ការងារសំខាន់ៗរបស់អង្គភាពស្ថិតិ គឺ ៖

- តាមដានតម្រូវការរបស់អ្នកប្រើប្រាស់
- ពិនិត្យបញ្ជីឈ្មោះប្រភពទិន្នន័យនៅវិទ្យាស្ថានជាតិស្ថិតិ សម្រាប់ការប្រើប្រាស់ទិន្នន័យដែលមានស្រាប់ និងសម្រាប់ចៀសវាងនូវការជាន់គ្នា
- រាយការណ៍ការអង្កេតថ្មីទៅវិទ្យាស្ថានជាតិស្ថិតិ មុននឹងចាប់ផ្តើមការងារ
- ប្រមូល កែច្នៃ ចងក្រង និងវិភាគទិន្នន័យ
- រាយការណ៍ប្រតិទិនប្រកាសផ្សាយ នៅលើវេបសាយរបស់វិទ្យាស្ថានជាតិស្ថិតិ
- ផ្សព្វផ្សាយលទ្ធផល និងផ្ញើស្ថិតិទៅវិទ្យាស្ថានជាតិស្ថិតិ ជាមួយឯកសារដែលចាំបាច់
- ទទួលយកមតិត្រឡប់ពីអ្នកប្រើប្រាស់។

# ៤ តម្រូវការស្ថិតិផ្លូវការដែលបានចាត់តាំង

យោងតាមច្បាប់ស្ដីពីស្ថិតិ មាត្រា ៤ សកម្មភាពស្ថិតិត្រូវដឹកនាំទៅតាមទិសដៅដូចខាងក្រោម ៖

- គាំទ្រសេចក្ដីត្រូវការទិន្នន័យស្ថិតិរបស់អ្នកធ្វើគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំវាយតម្លៃគោលនយោបាយ និងកម្មវិធីសេដ្ឋកិច្ច សង្គមកិច្ច ដែលផ្ដោតលើកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងសុខុមាលភាពរបស់ប្រទេសជាតិ ក៏ដូចជាសេចក្ដីត្រូវការសម្រាប់អ្នកធ្វើសេចក្ដីសម្រេចនិងអ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិ និងអន្តរជាតិដ៏ទូលំទូលាយ
- សម្រួលកិច្ចអភិវឌ្ឍន៍ប្រព័ន្ធស្ថិតិជាតិឲ្យមានសមត្ថភាព និងប្រសិទ្ធភាព
- បង្កើនការយល់ដឹងជាសាធារណៈ នូវសារៈសំខាន់អំពីមុខងារ និងតួនាទីរបស់ស្ថិតិនៅក្នុងកម្មវិធីអភិវឌ្ឍន៍ជាតិ
- លើកទឹកចិត្តដល់កិច្ចអភិវឌ្ឍន៍វិធីសាស្ត្រ និងបច្ចេកវិជ្ជានៅក្នុងសកម្មភាពស្ថិតិ។

អនុក្រឹត្យស្ដីពីស្ថិតិផ្លូវការដែលបានចាត់តាំងក៏បានពណ៌នាគោលដៅ "ដើម្បីបម្រើសំណូមពរព័ត៌មានស្ថិតិរបស់អ្នកធ្វើគោលនយោបាយក្នុងការរៀបចំ និងវាយតម្លៃគោលនយោបាយ និងកម្មវិធីសេដ្ឋកិច្ច សង្គមកិច្ចរបស់ប្រទេស ក៏ដូចជាសេចក្ដីត្រូវការព័ត៌មានរបស់អ្នកធ្វើសេចក្ដីសម្រេចចិត្ត និងអ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិ និងអន្តរជាតិដ៏ទូលំទូលាយ"។ ជាមួយគោលបំណងនោះ អ្នកផលិតស្ថិតិក្នុងប្រព័ន្ធស្ថិតិជាតិត្រូវផ្ដោតលើអ្នកប្រើប្រាស់ ក្នុងរាល់សកម្មភាពរបស់ខ្លួន ដើម្បីទទួលបាននូវគុណភាពតាមសេចក្ដីត្រូវការរបស់អ្នកធ្វើគោលនយោបាយ អ្នកធ្វើសេចក្ដីសម្រេចចិត្ត និងអ្នកស្រាវជ្រាវ។ សេចក្ដីត្រូវការរបស់អ្នកប្រើប្រាស់សម្រាប់ប្រព័ន្ធទាំងមូល ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងផែនការមេស្ថិតិ ដែលរៀបចំដោយវិទ្យាស្ថានជាតិស្ថិតិ និងពិភាក្សាដោយអ្នកពាក់ព័ន្ធសំខាន់ៗ មុននឹងទទួលការយល់ព្រមដោយក្រុមប្រឹក្សាស្ថិតិ នៅឆ្នាំ ២០០៧។ គន្លឹះណែនាំសំខាន់ៗក្នុងការបង្កើតស្ថិតិទាំងអស់នៅកម្ពុជា ទោះជាយ៉ាងណាក៏ដោយ គួរតែផលិតស្ថិតិតាមផែនការមេស្ថិតិ និងសូចនាករផ្សេងៗដែលត្រូវការ ឧទាហរណ៍សម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិថ្មី ឆ្នាំ ២០១០-២០១៥។ ការអនុវត្តន៍ផែនការមេស្ថិតិ ឆ្នាំ ២០០៨-២០១៥ មានសារៈសំខាន់ក្នុងការសម្របសម្រួលនៅពេលដែលធនធាននៅមានកម្រិត និងការអភិវឌ្ឍន៍ស្ថិតិជាតម្រូវការសម្រាប់កម្ពុជា។ ការងារអាស៊ានបច្ចុប្បន្នក្នុងប្រព័ន្ធស្ថិតិអាស៊ាន ក៏មានអត្ថប្រយោជន៍សម្រាប់ការអភិវឌ្ឍន៍ស្ថិតិនៅកម្ពុជាផងដែរ។ ក្របខ័ណ្ឌនៃប្រព័ន្ធស្ថិតិសហគមន៍អាស៊ាន ឆ្នាំ ២០១៥ នឹងទាមទារឲ្យមានការសម្របសម្រួលក្នុងប្រព័ន្ធស្ថិតិជាតិ។

លក្ខណៈវិនិច្ឆ័យគុណភាពស្ថិតិត្រូវបានយកមកពិចារណា និងយន្តការសម្របសម្រួលប្រើប្រាស់ជាឧបករណ៍ដើម្បីទទួលបានគុណភាពខ្ពស់។ ការសម្របសម្រួលស្ថិតិផ្ដល់នូវស្ថិតិដែល

អាចប្រៀបធៀបបាន និងអាចឲ្យអ្នកប្រើប្រាស់ធ្វើការវិភាគជាមួយប្រភពទិន្នន័យផ្សេងគ្នា។ មាត្រា ៣ នៃច្បាប់ស្ដីពីស្ថិតិ "ការអភិវឌ្ឍន៍ស្ថិតិត្រូវឈរលើមូលដ្ឋាននៃគោលការណ៍ភាពត្រឹមត្រូវ ភាពឯករាជ្យ ភាពសត្យានុម័ត ភាពគួរទុកចិត្តបាន ភាពសំខាន់ និងភាពទាន់ពេលវេលា"។ គោលការណ៍ទាំងនេះ គួរតែចងចាំជានិច្ច ក្នុងការផលិតស្ថិតិ។

គោលការណ៍ទី ១ *ភាពត្រឹមត្រូវ* មានន័យថា លទ្ធផលស្ថិតិគួរតែពណ៌នាឲ្យបានត្រឹមត្រូវអំពីបាតុភូតដែលត្រូវបានវាស់វែង។ នោះគឺលទ្ធផលស្ថិតិបង្ហាញពីការខិតជិតទៅរកតម្លៃពិតដែលអាចធ្វើទៅបាន។ គោលការណ៍ ទី ២ *ភាពឯករាជ្យ* មានន័យថា ស្ថិតិគួរតែផលិតដោយឯករាជ្យ និងផ្ដល់ព័ត៌មានជាសាធារណៈដោយមិនលំអៀងទៅរកសង្គមប្រជាធិបតេយ្យ។ គោលការណ៍ទី ៣ *ភាពសត្យានុម័ត* មានន័យថា ស្ថិតិដែលត្រូវផលិត គួរត្រូវបានសម្រេចតាមគោលការណ៍វិទ្យាសាស្ត្រ និងក្រមសីលធម៌វិជ្ជាជីវៈ អំពីវិធីសាស្ត្រ និងនីតិវិធីសម្រាប់ការផលិតស្ថិតិ។ គោលការណ៍ទី ៤ *ភាពគួរទុកចិត្តបាន* មានន័យថា លទ្ធផលស្ថិតិត្រូវវាស់វែងឲ្យមានភាពត្រូវគ្នា។ វាទាក់ទងយ៉ាងជិតស្និទ្ធនឹងភាពត្រឹមត្រូវ ប៉ុន្តែភាពគួរទុកចិត្តបានមិនបញ្ជាក់ពីភាពត្រឹមត្រូវឡើយ។ ខ្វះភាពត្រឹមត្រូវវានឹងមានផលតិចតួចដល់ភាពគួរទុកចិត្តបាន។ គោលការណ៍ទី ៥ *ភាពសំខាន់* មានន័យថា ស្ថិតិដែលបានផលិតបានបំពេញតម្រូវការពិតប្រាកដរបស់អ្នកប្រើប្រាស់។ ហេតុដូច្នេះ ទំនាក់ទំនងជាមួយអ្នកប្រើប្រាស់មានសារៈសំខាន់ណាស់ ដើម្បីរកឃើញនូវស្ថិតិដែលត្រូវផលិតសម្រាប់អ្នកប្រើប្រាស់។ គោលការណ៍ទី ៦ *ភាពទាន់ពេលវេលា* មានន័យថា ស្ថិតិត្រូវផ្សព្វផ្សាយឲ្យទាន់ពេលវេលាតាមដែលអាចធ្វើទៅបាន។ វាត្រូវបានគណនាជាពេល រវាងគ្រាគោល និងគ្រាផ្សព្វផ្សាយ។

ទិដ្ឋភាពផ្សេងទៀតដែលត្រូវពិចារណា គឺភាពអាចប្រៀបធៀបបាន និងភាពដែលអាចរកបានមានទំនាក់ទំនងជិតស្និទ្ធទៅនឹងភាពសំខាន់។ អ្នកប្រើប្រាស់ស្ថិតិចូលចិត្តទិន្នន័យដែលអាចប្រៀបធៀបបានតាមពេល និង/ឬរវាងការអង្កេតនានា។ ដើម្បីអាចប្រៀបធៀបការអង្កេត ម៉េតាទិន្នន័យជាមួយព័ត៌មានអំពីទស្សនៈ អថេរ និងចំណាត់ថ្នាក់ដែលប្រើប្រាស់គួរត្រូវបានបង្ហាញ។ ភាពអាចប្រៀបធៀបបាននឹងកើនឡើង បើស្ថិតិត្រូវបានសម្របសម្រួល។ បន្ទាប់មកអាចប្រើប្រាស់ស្ថិតិពីប្រភពផ្សេងៗគ្នានៅពេលវិភាគពីបញ្ហាជាក់លាក់មួយ។ ក្នុងប្រព័ន្ធសម្របសម្រួលស្ថិតិគ្មានការជាន់គ្នាតាមអថេរ ប្រជាជន និងគ្រាគោលឡើយ។ ស្ថិតិដែលបានផលិតក៏កំពុងប្រើប្រាស់ប្រព័ន្ធចំណាត់ថ្នាក់ទូទៅ វិធីសាស្ត្រទូទៅ និងឯកតាទូទៅ ប្រជាជន អថេរ និង/ឬគ្រាគោលផងដែរ។

ភាពដែលអាចរកបាននៃស្ថិតិត្រូវបានបញ្ជាក់ក្នុងច្បាប់ស្ដីពីស្ថិតិមាត្រា ១៩ បានចែងថាទិន្នន័យស្ថិតិដែលបានផលិតត្រូវបោះពុម្ព និងផ្សព្វផ្សាយដល់អ្នកប្រើប្រាស់ទាំងអស់។ ទិន្នន័យ និងម៉េតាទិន្នន័យអាចរកបានដោយងាយ ឧទាហរណ៍ នៅលើវេបសាយនឹងពង្រឹងគុណភាពសម្រាប់អ្នកប្រើប្រាស់។

ឧទាហរណ៍មួយចំនួនអំពីការសម្របសម្រួលគុណភាពកាលណា ៖

- អថេរ "គ្រួសារ" ត្រូវបានកំណត់តាមវិធីតែមួយ ក្នុងការចុះបញ្ជីរដ្ឋបាលពីរផ្សេងគ្នាដើម្បីប្រើប្រាស់រួមគ្នា
- ភាពត្រឹមត្រូវស្ថិតនៅក្នុងកម្រិតដូចគ្នា ក្នុងបីអង្កេតគំរូ ដើម្បីប្រើប្រាស់សម្រាប់ប្រៀបធៀបកម្រិតអប់រំ
- មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចស្វែងរកដោយងាយស្រួល នៅលើវេ៉សាយរបស់វិទ្យាស្ថានជាតិស្ថិតិនូវព័ត៌មាននានា នៅពេលដែលស្ថិតិសេដ្ឋកិច្ចផ្សេងៗត្រូវបានចេញផ្សាយ
- ពិពណ៌នាការអង្កេតផ្សេងៗដែលមានរចនាសម្ព័ន្ធដូចគ្នា ដែលធ្វើឲ្យអ្នកប្រើប្រាស់កាន់តែងាយស្រួលក្នុងការស្វែងរក ឧទាហរណ៍ និយមន័យអថេរសម្រាប់ការអង្កេតសំខាន់ៗ
- អ្នកប្រើប្រាស់អាចស្វែងរកស្ថិតិទាំងអស់ដែលបានចេញផ្សាយ នៅលើវេ៉បសាយរបស់វិទ្យាស្ថានជាតិស្ថិតិ។

# ៥ សកម្មភាពក្នុងប្រព័ន្ធស្ថិតិជាតិសម្រាប់ការសម្របសម្រួល និង កិច្ច សហប្រតិបត្តិការនៅឆ្នាំ ២០១០

នៅឆ្នាំ ២០១០ វិទ្យាស្ថានជាតិស្ថិតិបានរៀបចំអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំងដែលបានអនុម័តនៅខែ កក្កដា ឆ្នាំ ២០១០ នៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី ដែលមានសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ជាប្រធានអង្គប្រជុំ។ បន្ទាប់ពីនោះវិទ្យាស្ថានជាតិស្ថិតិបានអនុវត្តសកម្មភាពបន្ទាន់បំផុតមួយចំនួនដើម្បីគោរពទៅតាមច្បាប់ ឧទាហរណ៍ ការអង្កេតសន្និធិសមត្ថភាពមន្ត្រីស្ថិតិរបស់ក្រសួងពាក់ព័ន្ធក្នុងប្រព័ន្ធស្ថិតិជាតិ និងការប្រមូលម៉េតាទិន្នន័យដែលមានលក្ខណៈតូចជាង។ សន្និធិសមត្ថភាពមន្ត្រីស្ថិតិត្រូវបានប្រើប្រាស់ ដើម្បីតាមដានស្ថានភាពបច្ចុប្បន្នរបស់មន្ត្រីជំនាញក្នុងប្រព័ន្ធស្ថិតិជាតិ និងសេចក្តីត្រូវការដែលគាំទ្រពីវិទ្យាស្ថានជាតិស្ថិតិ។ ម៉េតាទិន្នន័យនឹងត្រូវរក្សាទុកនៅក្នុងទិន្នន័យមូលដ្ឋាន និងបញ្ជីឈ្មោះស្ថិតិផ្លូវការដែលបានចាត់តាំងដែលនឹងបញ្ចប់នៅឆ្នាំ ២០១១។ ព័ត៌មានមួយចំនួនពីការប្រមូលទិន្នន័យទាំងនេះត្រូវបានបង្ហាញក្នុងជំពូក ៦ ។

វិទ្យាស្ថានជាតិស្ថិតិក៏មានទីប្រឹក្សារយៈពេលខ្លីមកពីប្រទេសស៊ុយអែត ដើម្បីជួយដល់ការកំណត់អាទិភាពសកម្មភាពចាំបាច់បំផុត ដែលតម្រូវឲ្យអនុវត្តនៅឆ្នាំ ២០១០។

## ៥.១ អនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង

មាត្រា ១៣ នៃច្បាប់ស្តីពីស្ថិតិបានចែងថា វិទ្យាស្ថានជាតិស្ថិតិស្ថិតក្រោមឱវាទក្រសួងផែនការមានភារកិច្ចកសាងគោលនយោបាយស្ថិតិផ្លូវការ ក្នុងការបង្កើតប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយដែល

គ្របដណ្តប់ស្ថិតិផ្លូវការដែលបានចាត់តាំងទាំងអស់ និងអង្គភាពស្ថិតិក្នុងក្រសួង ស្ថាប័ន។ ដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការដែលបានចាត់តាំង ត្រូវកំណត់ដោយអនុក្រឹត្យ។

យោងតាមច្បាប់ស្តីពីស្ថិតិ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង។

អនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង ត្រូវបានព្រាងលើកដំបូងបង្អស់នៅខែ សីហា ឆ្នាំ ២០០៣ ដោយទីប្រឹក្សាស្ថិតិពហុវិស័យ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) នៅវិទ្យាស្ថានជាតិស្ថិតិ។ បន្ទាប់មក ពង្រាងនេះត្រូវបានកែប្រែនៅខែ កញ្ញា ឆ្នាំ ២០០៥ ដោយអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ បន្ទាប់ពីច្បាប់ស្តីពីស្ថិតិត្រូវបានអនុម័តនៅខែ ឧសភា ឆ្នាំ ២០០៥។

អនុក្រឹត្យនេះត្រូវបានផ្តល់ប្រឹក្សា និងទស្សនៈល្អៗដោយទីប្រឹក្សា IMF ទីប្រឹក្សារបស់គម្រោង Sida នៅវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងជាពិសេសមតិល្អៗដែលទទួលបានពីអង្គប្រជុំចំនួនពីរដងនៃគណៈកម្មាធិការសម្របសម្រួលស្ថិតិ ដែលគ្រប់ក្រសួងពាក់ព័ន្ធជាសមាជិកបានធ្វើការកែលម្អ។ ជាមួយគ្នានេះដែរ ការរៀបចំពង្រាងនេះក៏ផ្អែកតាមស្ថានភាពជាក់ស្តែងរបស់ប្រព័ន្ធស្ថិតិជាតិបច្ចុប្បន្នផងដែរ។

អត្ថន័យនៃអនុក្រឹត្យនេះត្រូវបានអនុវត្តតាមច្បាប់ស្តីពីស្ថិតិដែលបានអនុម័តនៅថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០០៥ ហើយអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិដែលបានប្រកាសឲ្យប្រើនៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៧។

សេចក្តីព្រាងអនុក្រឹត្យនេះក៏ត្រូវបានពិភាក្សា និងពិនិត្យឡើងវិញដើម្បីឲ្យមានភាពល្អប្រសើរដោយក្រុមប្រឹក្សាអ្នកច្បាប់ គណៈកម្មការភាសាវិទ្យាខ្មែរ និងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅក្នុងអង្គប្រជុំលើកដំបូងនាថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១០។

បន្ទាប់មកសេចក្តីព្រាងអនុក្រឹត្យនេះត្រូវបានដាក់ឆ្លងអង្គប្រជុំអន្តរក្រសួងនៅថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១០ ដើម្បីពិនិត្យ និងសម្រេចចុងក្រោយនូវភារកិច្ចរបស់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលនីមួយៗ សម្រាប់អនុវត្តឲ្យបានក្រោយពេលអនុក្រឹត្យនេះចូលជាធរមាន។

សេចក្តីព្រាងអនុក្រឹត្យត្រូវបានយកមកពិភាក្សានៅក្នុងអង្គប្រជុំចុងក្រោយ ក្រោមអធិបតីភាពឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យមុននឹងដាក់ជូនអង្គប្រជុំគណៈរដ្ឋមន្ត្រីដើម្បីឆ្លងសម្រេច។

ជាចុងក្រោយ អនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង ត្រូវបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១០ ហើយត្រូវបានចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី នៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១០។

## ៥.២ សន្និធិសមត្ថភាព ( Competence Inventory )

នៅឆ្នាំ ២០១០ វិទ្យាស្ថានជាតិស្ថិតិបានប្រមូលព័ត៌មានអំពីជំនាញរបស់មន្ត្រីក្នុងប្រព័ន្ធស្ថិតិជាតិ។ គោលបំណងនៃការអង្កេតសន្និធិស្ថិតិផ្លូវការ គឺដើម្បីតាមដានចំនួនមន្ត្រីក្នុងប្រព័ន្ធស្ថិតិជាតិ និងជំនាញរបស់ពួកគេ ដើម្បីបំពេញការងារជាអ្នកផលិតស្ថិតិផ្លូវការដែលបានចាត់តាំង។ សំណូមពររបស់គណៈកម្មាធិការសម្របសម្រួលស្ថិតិ អំពីការសម្របសម្រួលសកម្មភាពបណ្តុះបណ្តាលផ្សេងៗ គឺជាលទ្ធផលនៃការអង្កេតសន្និធិស្ថិតិផ្លូវការនេះ ។

សេចក្តីព្រាងការអង្កេតត្រូវបានពិភាក្សាផ្ទៃក្នុង និងបន្ទាប់មកសេចក្តីព្រាងចុងក្រោយត្រូវបានដាក់ឆ្លងក្នុងអង្គប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិ នាថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ២០១០។ សេចក្តីព្រាងការអង្កេតចុងក្រោយត្រូវបានពិភាក្សា និងទទួលការឯកភាពបន្ទាប់ពីកែតម្រូវមួយចំនួន។ ពីរសប្តាហ៍បន្ទាប់ពីអង្គប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិ បញ្ជីសំណួរអង្កេតត្រូវបានផ្ញើទៅក្រសួង ស្ថាប័នដែលទទួលខុសត្រូវលើស្ថិតិផ្លូវការដែលបានចាត់តាំង។

ក្នុងអង្គប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិ នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១០ វិទ្យាស្ថានស្ថិតិជាតិបានធ្វើបទបង្ហាញអំពីលទ្ធផលបឋមមួយចំនួន ពីការអង្កេតលើក្រសួង ស្ថាប័នពាក់ព័ន្ធដែលបានផ្តល់ព័ត៌មានមក។ ក្រសួង ស្ថាប័នដែលមិនបានឆ្លើយតបត្រូវបានស្នើសុំឲ្យផ្ញើព័ត៌មានអង្កេតមកឲ្យបានឆាប់ដែលអាចធ្វើទៅបាន។

នៅពេលវិទ្យាស្ថានជាតិស្ថិតិចាប់ផ្តើមប្រមូលម៉េតាទិន្នន័យនៅក្នុងខែ មករា ឆ្នាំ ២០១១ វិទ្យាស្ថានជាតិស្ថិតិបានធ្វើការរំលឹកជាលើកចុងក្រោយ អំពីការអង្កេតសន្និធិសមត្ថភាព។ ប៉ុន្តែនៅតែមិនមានការឆ្លើយតបមកកាន់វិទ្យាស្ថានជាតិស្ថិតិ។ ជាសរុបមានក្រសួងចំនួន ១៧ ដែលបានធ្វើការឆ្លើយតប។

## ៥.៣ ការប្រមូលម៉េតាទិន្នន័យ

ដើម្បីរៀបចំបញ្ជីឈ្មោះម៉េតាទិន្នន័យរបស់ប្រព័ន្ធស្ថិតិជាតិ វិទ្យាស្ថានជាតិស្ថិតិបានធ្វើការប្រមូលម៉េតាទិន្នន័យមួយចំនួនពីអង្គភាពស្ថិតិដែលបានចាត់តាំង។ ពង្រាងបញ្ជីសំណួរត្រូវបានយកមកពិភាក្សាក្នុងអង្គប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិ នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១០ ហើយពីរសប្តាហ៍ក្រោយមក បញ្ជីសំណួរត្រូវបានផ្ញើទៅអង្គភាពស្ថិតិដែលបានចាត់តាំង។ ការងារនឹងបន្តដល់ឆ្នាំ ២០១១ ដើម្បីបង្ហាញម៉េតាទិន្នន័យក្នុងបញ្ជីឈ្មោះ និងដើម្បីពិភាក្សាជាមួយសមាជិកគណៈកម្មាធិការសម្របសម្រួលស្ថិតិ និងក្រុមប្រឹក្សាស្ថិតិអំពីវិធីសាស្ត្រសម្របសម្រួលការងារដើម្បីប្រើប្រាស់សមត្ថភាព និងធនធានសម្រាប់ស្ថិតិប្រកបដោយប្រសិទ្ធភាព។

### ៥.៤ សិក្ខាសាលាសម្រាប់សមាជិកគណៈកម្មាធិការសម្របសម្រួលស្ថិតិ

នៅខែ វិច្ឆិកា ឆ្នាំ ២០១០ វិទ្យាស្ថានជាតិស្ថិតិបានរៀបចំសិក្ខាសាលាសម្រាប់សមាជិកគណៈកម្មាធិការសម្របសម្រួលស្ថិតិស្ដីពីការផលិតទិន្នន័យផ្លូវការដែលបានចាត់តាំង ដោយមានអ្នកចូលរួមជាង ៥០ នាក់។ ឯកឧត្តមអគ្គនាយក **សន ស៊ីថន** បានធ្វើបទបង្ហាញអំពីប្រព័ន្ធស្ថិតិជាតិកម្ពុជា និងទីប្រឹក្សារយៈពេលខ្លីរបស់ Sida ធ្វើបទបង្ហាញអំពីមូលហេតុនៃការសម្របសម្រួល និងអ្វីដែលត្រូវដឹងក្នុងនាមជាអ្នកផលិតស្ថិតិផ្លូវការដែលបានចាត់តាំង។

# ៦ ប្រព័ន្ធស្ថិតិជាតិឆ្នាំ ២០១០

### ៦.១ ធនធាននៅក្នុងប្រព័ន្ធស្ថិតិជាតិ ឆ្នាំ ២០១០

យោងតាមច្បាប់គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ដែលទទួលខុសត្រូវស្ថិតិផ្លូវការដែលបានចាត់តាំង តម្រូវឲ្យបង្កើតអង្គភាពមួយសម្រាប់ផលិតស្ថិតិនេះ។ ក្រសួង ស្ថាប័នពាក់ព័ន្ធក៏តម្រូវឲ្យផ្ញើព័ត៌មានទៅវិទ្យាស្ថានជាតិស្ថិតិ អំពីការចំណាយសម្រាប់ការប្រមូលទិន្នន័យ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែថវិកាមិនមានការចែករំលែកថ្នាក់ក្រោម វាមានការលំបាកក្នុងការគណនាចំណាយសរុប។ ក្រសួង ស្ថាប័នមួយចំនួនបានធ្វើការប៉ាន់ស្មានតែលើប្រាក់បៀវត្សរ៍របស់មន្ត្រីប៉ុណ្ណោះ ចំណែកឯក្រសួង ស្ថាប័នផ្សេងទៀតអាចមានលទ្ធភាពបញ្ចូលរាល់ការចំណាយទាំងអស់។ ឧបករណ៍ព័ត៌មានវិទ្យា (ICT) និងជំនួយរបស់ដៃគូអភិវឌ្ឍន៍សម្រាប់ការប្រមូលទិន្នន័យគួរត្រូវបានដាក់បញ្ចូល។

នៅក្រោមក្រសួងពាក់ព័ន្ធនីមួយៗមានព័ត៌មានអំពីចំនួនមន្ត្រី និងថវិកាសរុបសម្រាប់អង្គភាពស្ថិតិដែលបានចាត់តាំងប្រសិនបើមាន។ មុនពេលបោះពុម្ពរបាយការណ៍ប្រចាំឆ្នាំនៅឆ្នាំក្រោយ សមាជិកគណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវពិភាក្សាអំពីវិធីសាស្ត្រប្រមូលព័ត៌មាន តាមកម្រិតបទដ្ឋានមួយខ្ពស់។

មន្ត្រីសរុបដែលកំពុងធ្វើការជាមួយស្ថិតិផ្លូវការដែលបានចាត់តាំងនៅវិទ្យាស្ថានជាតិស្ថិតិមានចំនួន ៣១៤ នាក់ និងអង្គភាពស្ថិតិដែលបានចាត់តាំងនៅតាមក្រសួងពាក់ព័ន្ធ និងធនាគារជាតិនៃកម្ពុជាមានចំនួន ២៩០ នាក់។

### ៦.២ កម្រិតសមត្ថភាពក្នុងប្រព័ន្ធស្ថិតិជាតិ នៅខែ វិច្ឆិកា ឆ្នាំ ២០១០

លទ្ធផលនៃការអង្កេតឆ្នាំ ២០១០ អំពីកម្រិតសមត្ថភាពនៅអង្គភាពស្ថិតិដែលបានចាត់តាំងបង្ហាញថា ប្រមាណពាក់កណ្ដាល នៃមន្ត្រីនៅអង្គភាពស្ថិតិដែលទទួលខុសត្រូវលើស្ថិតិផ្លូវការដែលបានចាត់តាំងមានសញ្ញាប័ត្រវិទ្យាល័យគឺ ២៩ ភាគរយមានបរិញ្ញាប័ត្រ ២១ ភាគរយមានសញ្ញាប័ត្រអនុបណ្ឌិត និង ១ ភាគរយមានសញ្ញាប័ត្របណ្ឌិត។ តែ ១ ភាគ ៣ នៃមន្ត្រីប៉ុណ្ណោះ អាចមានជំនាញ

គ្រប់គ្រាន់ (ជំនាញស្ថិតិខ្ពស់ ឬខ្ពស់ខ្លាំង) ដើម្បីបំពេញការងារក្នុងអង្គភាពស្ថិតិ។ ចំនួនមន្ត្រីដែលមានជំនាញស្ថិតិខ្ពស់ខ្លាំង មិនមានគ្រប់គ្រាន់សម្រាប់ការផលិតស្ថិតិក្នុងប្រព័ន្ធស្ថិតិជាតិឡើយ ហេតុដូច្នេះតម្រូវឲ្យមានការបណ្តុះបណ្តាលស្ថិតិ។ ការផលិតស្ថិតិនាពេលបច្ចុប្បន្ន គឺអាស្រ័យលើឧបករណ៍សម្ភារៈព័ត៌មានវិទ្យាផ្សេងៗ ហើយលទ្ធផលពីអង្កេតដែលបានសួរក្នុងការអង្កេតបានបង្ហាញថាមានសេចក្តីត្រូវការខាងការបណ្តុះបណ្តាលព័ត៌មានវិទ្យា។ សមត្ថភាពនៃការសរសេរ និងនិយាយភាសាអង់គ្លេស គឺស្ថិតនៅកម្រិតមធ្យមសម្រាប់មន្ត្រីភាគច្រើនក្នុងប្រព័ន្ធស្ថិតិជាតិ ហេតុដូច្នេះការបណ្តុះបណ្តាលក៏ជាតម្រូវការផងដែរ ក្នុងផ្នែកនេះ។

ការបណ្តុះបណ្តាលស្ថិតិមូលដ្ឋានជាតម្រូវការសម្រាប់មន្ត្រីភាគច្រើន ក្នុងអង្គភាពស្ថិតិដែលបានចាត់តាំង។ ផ្នែកនេះនៅមានកម្រិតទាបខ្លាំង និងមិនគ្រប់គ្រាន់ដើម្បីផលិតស្ថិតិក្នុងក្រសួងពាក់ព័ន្ធ។ មន្ត្រីមួយចំនួនមានជំនាញគ្រប់គ្រាន់ដើម្បីចូលរួមក្នុងវគ្គសិក្សាផ្នែកស្ថិតិ ឬធ្វើការវិភាគកម្រិតមធ្យម។ មន្ត្រីដែលមានជំនាញស្ថិតិខ្ពស់ក៏ត្រូវការបណ្តុះបណ្តាលបន្ថែមទៀត ជាពិសេសការធ្វើវិភាគ។

ភាសាអង់គ្លេសមានសារៈសំខាន់ណាស់ និងត្រូវបានផ្តល់អនុសាសន៍។ នៅពេលដែលភាសាអង់គ្លេសជាជំនាញដែលត្រូវការសម្រាប់ការងារផ្សេងៗជាច្រើននៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ និងមន្ត្រីជាច្រើនត្រូវការការបណ្តុះបណ្តាលនេះ ក្រសួងនីមួយៗត្រូវតែទទួលខុសត្រូវលើការបណ្តុះបណ្តាលមន្ត្រីរបស់ខ្លួន។

ការបណ្តុះបណ្តាលតាមរយៈការងារ ជាមួយវគ្គបណ្តុះបណ្តាលត្រូវបានផ្តល់អនុសាសន៍ដើម្បីបង្កើនចំណេះដឹងកាន់តែស៊ីជម្រៅ និងបានប្រើប្រាស់ការបណ្តុះបណ្តាលនេះ។ ក្រសួង ស្ថាប័ននីមួយៗត្រូវទទួលខុសត្រូវក្នុងការរៀបចំការបណ្តុះបណ្តាលតាមរយៈការងារ។

## ៦.៣ ការបោះពុម្ពផ្សាយក្នុងប្រព័ន្ធស្ថិតិជាតិ

យោងតាមអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង មិនមែនទិន្នន័យទាំងអស់ឡើយដែលត្រូវបានប្រមូល ឬបោះពុម្ព។ ក្នុងផ្នែក ៦.៤ ស្ថិតិផ្លូវការដែលបានចាត់តាំងរបស់វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដទៃទៀត ត្រូវបានបង្ហាញដោយផ្អែកលើការអង្កេតដែលពួកគេទទួលខុសត្រូវក្នុងអនុក្រឹត្យ។ ទិន្នន័យមួយចំនួនត្រូវបានប្រមូល ប៉ុន្តែមិនទាន់បោះពុម្ពនៅឡើយ។ ទិន្នន័យផ្សេងទៀតគ្រាន់តែមានសម្រាប់ក្រសួងតែប៉ុណ្ណោះ ហើយបើដឹងអាចស្នើសុំដោយអ្នកប្រើប្រាស់។ ដើម្បីចាត់ទុកជាស្ថិតិផ្លូវការដែលបានចាត់តាំង ទោះជាយ៉ាងណាក៏ដោយស្ថិតិត្រូវការបោះពុម្ពផ្សាយដល់អ្នកប្រើប្រាស់ទាំងអស់។ នេះគឺជាអ្វីដែលត្រូវការធ្វើឲ្យប្រសើរឡើងនៅឆ្នាំក្រោយ។

បើរបាយការណ៍មានឈ្មោះ ហើយគ្មានកាលបរិច្ឆេទត្រូវបានបោះផ្សាយដូចបង្ហាញខាងក្រោម របាយការណ៍នោះមិនបោះពុម្ពផ្សាយជាផ្លូវការឡើយ។

## ៦.៤ វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង

### ៦.៤.១ វិទ្យាស្ថានជាតិស្ថិតិ

ក្រៅពីការងារសម្របសម្រួលដែលបានរៀបរាប់ក្នុងផ្នែក ៣.៥ វិទ្យាស្ថានជាតិស្ថិតិមានភារកិច្ចទទួលខុសត្រូវលើការណែនាំ និងការគ្រប់គ្រងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងស្ថិតិនៅព្រះរាជាណាចក្រកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយការងារចម្បងសម្រាប់វិទ្យាស្ថានជាតិស្ថិតិគឺការប្រមូលទិន្នន័យស្ថិតិ។ រាល់ទិន្នន័យដែលប្រកាសផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ គឺជាស្ថិតិផ្លូវការដែលបានចាត់តាំង។

ចំនួនមន្ត្រី ៖ ៣១៤ នាក់

ថវិកាសម្រាប់វិទ្យាស្ថានជាតិស្ថិតិ ៖ ៥.២០៨.០០០ ដុល្លារអាមេរិក

ស្ថិតិផ្លូវការដែលបានចាត់តាំងរបស់វិទ្យាស្ថានជាតិស្ថិតិ រួមមាន ៖

**១. ស្ថិតិជំរឿន**

- ស្ថិតិជំរឿនប្រជាជន រៀងរាល់ ១០ឆ្នាំម្តង
- ស្ថិតិជំរឿនកសិកម្ម រៀងរាល់ ១០ឆ្នាំម្តង
- ស្ថិតិជំរឿនសហគ្រាស រៀងរាល់ ១០ឆ្នាំម្តង។

**២. ស្ថិតិអង្កេត**

- ស្ថិតិអង្កេតប្រជាពាស្ត្រចន្លោះជំរឿន រៀងរាល់ ១០ឆ្នាំម្តង
- ស្ថិតិអង្កេតការអប់រំ និងអក្ខរភាព រៀងរាល់ ៥ឆ្នាំម្តង
- ស្ថិតិអង្កេតប្រជាសាស្ត្រ និងសុខភាព រៀងរាល់ ៥ឆ្នាំម្តង
- ស្ថិតិអង្កេតផ្នែកមិនរៀបរយ និងសេដ្ឋកិច្ចមិនបានពិនិត្យ រៀងរាល់ ៥ឆ្នាំម្តង
- ស្ថិតិអង្កេតឧក្រិដ្ឋកម្ម និងយុត្តិធម៌ រៀងរាល់ ៥ឆ្នាំម្តង
- ស្ថិតិអង្កេតសហគ្រាស ប្រចាំឆ្នាំ
- ស្ថិតិអង្កេតកម្លាំងពលកម្ម ប្រចាំឆ្នាំ
- ស្ថិតិអង្កេតហិរញ្ញវត្ថុវិស័យកសិកម្ម ប្រចាំឆ្នាំ
- ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ប្រចាំឆ្នាំ
- ស្ថិតិអង្កេតប្រជាសាស្ត្រ
- ស្ថិតិអង្កេតពលកម្មកុមារ។

**៣. ស្ថិតិសេដ្ឋកិច្ច**

- ស្ថិតិចុះបញ្ជីអាជីវកម្មសមាហរណកម្ម ប្រចាំឆ្នាំ
- ស្ថិតិគណនេយ្យជាតិ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- សន្ទស្សន៍ផលិតកម្មកសិកម្ម និងឧស្សាហកម្ម ប្រចាំត្រីមាស និងប្រចាំឆ្នាំ

- ស្ថិតិ និងសន្ទស្សន៍ពាណិជ្ជកម្មលក់រាយ និងលក់ដុំ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- សន្ទស្សន៍ថ្លៃនីហារ៍ណ និងអាហារ៍ណ ប្រចាំខែ និងប្រចាំត្រីមាស
- គណនីរណបតាមផ្នែក
- សន្ទស្សន៍ចំណាយពលកម្ម និងថ្លៃឈ្នួល
- សន្ទស្សន៍ថ្លៃអ្នកផលិត និងសេវាកម្ម។

### ៤. ស្ថិតិបរិស្ថាន និងធនធានធម្មជាតិ

- ស្ថិតិបរិស្ថាន និងធនធានធម្មជាតិ
- គណនីរណបបរិស្ថាន និងធនធានធម្មជាតិ។

### ៥. ស្ថិតិសង្គមកិច្ច និងប្រជាសាស្ត្រ

- ស្ថិតិប្រជាសាស្ត្រ និងប្រជារាស្ត្រ ប្រចាំឆ្នាំ
- ស្ថិតិចំណូល និងចំណាយគ្រួសារ ប្រចាំឆ្នាំ
- ស្ថិតិសង្គមកិច្ចផ្សេងទៀត ប្រចាំឆ្នាំ។

### ៦. កម្រងស្ថិតិ

- សៀវភៅស្ថិតិថ្នាក់ជាតិ រាជធានី ខេត្ត ប្រចាំឆ្នាំ
- សៀវភៅស្ថិតិថ្នាក់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ប្រចាំឆ្នាំ
- សូចនាករសេដ្ឋកិច្ច និងបរិស្ថាន ប្រចាំឆ្នាំ និង
- សូចនាករសង្គមកិច្ច ប្រជាសាស្ត្រ ប្រចាំឆ្នាំ។

## ស្ថិតិផ្លូវការដែលបានចាត់តាំងបោះពុម្ពផ្សាយ ដោយវិទ្យាស្ថានជាតិស្ថិតិ

| ឈ្មោះស្ថិតិ | គ្រាគោល | ទិន្នន័យបោះពុម្ពផ្សាយចុងក្រោយ | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិជំរឿនប្រជារាស្ត្រ<br>(សូមមើលឧបសម្ព័ន្ធ ២) | ២០០៨ | ២០០៩ | ជំរឿនប្រជារាស្ត្រទូទៅនៅកម្ពុជា ឆ្នាំ ២០០៨<br>របាយការណ៍ជាតិស្តីពីលទ្ធផលជំរឿន ខែសីហា ឆ្នាំ ២០០៩ |
| | - | ២០១០ | របាយការណ៍ជំរឿនខេត្ត ឆ្នាំ ២០១០ |
| | | ២០១០ | របាយការណ៍វិភាគស៊ីជម្រៅនៃជំរឿនប្រជារាស្ត្រ ឆ្នាំ ២០០៨ មាន១៤ ប្រធានបទ។ ប្រធានបទរួមមាន ៖<br>១. លទ្ធភាពបង្កើតកូន និងមរណភាព<br>២. កំណើន និងបម្រែបម្រួលប្រជារាស្ត្រតាមការបែងចែកទីតាំង<br>៣. ស្ថានភាពអាពាហ៍ពិពាហ៍<br>៤. សមាសធាតុភេទ និងអាយុ |

| | | | |
|---|---|---|---|
| | | | ៥. ពិការភាព<br>៦. ការផ្លាស់ប្តូរទីលំនៅ<br>៧. អក្ខរកម្ម និងការសិក្សា<br>៨. សកម្មភាពសេដ្ឋកិច្ច និងការងារ<br>៩. ចលនាប្រជារាស្ត្រពេលថ្ងៃ<br>១០. លំនៅដ្ឋាន និងការប្រើប្រាស់របស់គ្រួសារ<br>១១. គ្រួសារ និងផ្ទះសម្បែង<br>១២. ចំណោលប្រជារាស្ត្រកម្ពុជា<br>១៣. ស្ថានភាពស្ត្រីនៅកម្ពុជា<br>១៤. ការអភិវឌ្ឍន៍ទីប្រជុំជននៅកម្ពុជា |
| | | ២០១០ | ផែនទីស្ថិតិ និងសៀវភៅផែនទីជំរឿន |
| ស្ថិតិជំរឿនកសិកម្ម | - | - | - |
| ស្ថិតិជំរឿនសហគ្រាស | ២០១១ | - | - |
| ស្ថិតិអង្កេតប្រជារាស្ត្រចន្លោះជំរឿន | ២០០៤ | ២០០៤ | ការអង្កេតប្រជារាស្ត្រចន្លោះជំរឿនកម្ពុជា ឆ្នាំ ២០០៤ |
| ស្ថិតិអង្កេតការអប់រំ និងអក្ខរភាព | ២០០៩ | ២០១០ | ការអង្កេតស្ថិតិសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ ២០០៩ |
| ស្ថិតិអង្កេតប្រជាសាស្ត្រ និងសុខភាព | ២០០៥ | ២០០៦ | ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ ២០០៥ |
| ស្ថិតិអង្កេតផ្នែកមិនរៀបរយ និងសេដ្ឋកិច្ចមិនបានពិនិត្យ | ២០០៨ | ២០១០ | ព្រឹត្តិបត្រគណនេយ្យជាតិកម្ពុជា ឆ្នាំ១៩៩៣-២០០៨ លេខ ១៣ |
| ស្ថិតិអង្កេតឧក្រិដ្ឋកម្ម និងយុត្តិធម៌ | - | - | - |
| ស្ថិតិចុះបញ្ជីសហគ្រាស | ២០០៩ | ២០០៩ | ការធ្វើបញ្ជីសហគ្រាសទូទាំងប្រទេសកម្ពុជា ឆ្នាំ ២០០៩ |
| ស្ថិតិអង្កេតសហគ្រាស | ២០១០ | ២០១០ | លទ្ធផលបឋមនៃការអង្កេតសាកល្បងស្តីពីជំរឿនសហគ្រាសកម្ពុជា ឆ្នាំ ២០១០ |
| ស្ថិតិអង្កេតកម្លាំងពលកម្ម | ២០០១ | ២០០១ | ការអង្កេតកម្លាំងពលកម្មកម្ពុជា |
| ស្ថិតិអង្កេតហិរញ្ញវត្ថុកសិកម្ម | ២០០៥ | ២០០៥ | ស្ថិតិហិរញ្ញវត្ថុកសិកម្ម |
| ស្ថិតិអង្កេតសេដ្ឋកិច្ច សង្គមកិច្ច | ២០០៩ | ២០១០ | ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ ២០០៩ |
| ស្ថិតិអង្កេតប្រជាសាស្ត្រ | ១៩៩៦ | ១៩៩៦ | ការអង្កេតប្រជាសាស្ត្រកម្ពុជា ឆ្នាំ ១៩៩៦ |
| | | ២០០៤ | របាយការណ៍ទូទៅឆ្នាំ ២០០៤ |
| ស្ថិតិអង្កេតពលកម្មកុមារ | ២០០១ | ២០០១ | របាយការណ៍ស្តីពីការអង្កេតពលកម្មកុមារ |
| ស្ថិតិចុះបញ្ជីអាជីវកម្មសមាហរណកម្ម | - | - | - |
| ស្ថិតិគណនេយ្យជាតិ | ២០០៨ | ២០១០ | ព្រឹត្តិបត្រគណនេយ្យជាតិកម្ពុជា ឆ្នាំ១៩៩៣-២០០៨ លេខ ១៣ |
| សន្ទស្សន៍ផលិតកម្មកសិកម្ម និងឧស្សាហកម្ម | ២០០៨ | ២០១០ | ព្រឹត្តិបត្រគណនេយ្យជាតិកម្ពុជា ឆ្នាំ១៩៩៣-២០០៨ លេខ ១៣ |
| ស្ថិតិ និងសន្ទស្សន៍ពាណិជ្ជកម្មលក់រាយ និងលក់ដុំ | ២០០៨ | ២០១០ | ព្រឹត្តិបត្រគណនេយ្យជាតិកម្ពុជា ឆ្នាំ១៩៩៣-២០០៨ លេខ ១៣ |
| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ | ២០០៧ | ២០០៨ | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ កម្ពុជា<br>(ខែមិនា ឆ្នាំ២០០៤ ដល់ ខែធ្នូ ឆ្នាំ២០០៧) |

| | | | |
|---|---|---|---|
| | ២០១០ | ២០១០-២០១១ | ព្រឹត្តិបត្រសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ប្រចាំខែ |
| សន្ទស្សន៍ថ្លៃនីហាវ័ណ និងអាហាវ័ណ | ២០០៩ | ២០១០ | ស្ថិតិពាណិជ្ជកម្ម |
| គណនីវេណបតាមផ្នែក | - | - | - |
| សន្ទស្សន៍ចំណាយពលកម្ម និងថ្លៃឈ្នួល | ២០០៩ | ២០១០ | ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ ២០០៩ |
| សន្ទស្សន៍ថ្លៃអ្នកផលិត និងសេវាកម្ម | ២០០៧ | ២០០៨ | សន្ទស្សន៍ថ្លៃផលិតករ កម្ពុជា<br>(ខែធ្នូ ឆ្នាំ២០០៣ ដល់ខែមីនា ឆ្នាំ២០០៧) |
| ស្ថិតិបរិស្ថាន និងធនធានធម្មជាតិ | - | - | - |
| គណនីវេណបបរិស្ថាន និងធនធានធម្មជាតិ | - | - | - |
| ស្ថិតិប្រជាសាស្ត្រ និងប្រជារាស្ត្រ | - | - | - |
| ស្ថិតិចំណូល និងចំណាយគ្រួសារ | - | - | - |
| ស្ថិតិសង្គមកិច្ចផ្សេងទៀត | ២០០៧ | ២០១០ | ស្ថិតិសង្គមកិច្ចប្រចាំឆ្នាំ ២០០៨ |
| ស្ថិតិអង្កេតមនុស្សមាឌ | ២០០៨ | ២០០៩ | របាយការណ៍ស្តីពីការអង្កេតមនុស្សមាឌ |
| និន្នាការកម្លាំងពលកម្ម និងសង្គម | ២០១០ | ២០១០ | និន្នាការកម្លាំងពលកម្ម និងសង្គមនៅកម្ពុជា ឆ្នាំ២០១០ |
| សៀវភៅស្ថិតិប្រចាំឆ្នាំ ថ្នាក់ជាតិ ក្រុង ខេត្ត | ២០០៧ | ២០០៨ | សៀវភៅស្ថិតិប្រចាំឆ្នាំនៅកម្ពុជា ឆ្នាំ ២០០៨ |
| សៀវភៅស្ថិតិ តាមខេត្ត | ២០១០ | ២០១០ | សៀវភៅប្រចាំឆ្នាំ តាមខេត្ត |
| សៀវភៅស្ថិតិថ្នាក់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ | - | - | - |
| សូចនាករសេដ្ឋកិច្ច និងបរិស្ថាន | - | - | - |
| សូចនាករសង្គមកិច្ច ប្រជាសាស្ត្រ | - | - | - |

### ៦.៤.២ ទីស្តីការគណៈរដ្ឋមន្ត្រី

ទីស្តីការគណៈរដ្ឋមន្ត្រីជាសេនាធិការឲ្យនាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រី សម្របសម្រួលការងារលើគ្រប់វិស័យ ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា។

ចំនួនមន្ត្រីក្នុងអង្គភាពស្ថិតិដែលបានចាត់តាំង ៖ ៨ នាក់

ថវិកាប៉ាន់ស្មានសម្រាប់អង្គភាពស្ថិតិដែលបានចាត់តាំង ៖ ៨.៩៤០ ដុល្លារអាមេរិក

ស្ថិតិផ្លូវការដែលបានចាត់តាំងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលទទួលខុសត្រូវ ៖

- ស្ថិតិវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ ប្រចាំខែ និងប្រចាំឆ្នាំ។

### ស្ថិតិផ្លូវការដែលបានចាត់តាំងបោះពុម្ពផ្សាយ ដោយទីស្តីការគណៈរដ្ឋមន្ត្រី

| ឈ្មោះស្ថិតិ | គ្រាគោល | ទិន្នន័យបោះពុម្ពផ្សាយចុងក្រោយ | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ២០១០ | ២០១០ | ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ខែ មិនា ឆ្នាំ ២០១០ |

## ៦.៤.៣ ក្រសួងមហាផ្ទៃ

ភារកិច្ចរបស់ក្រសួងមហាផ្ទៃ គឺណែនាំ និងត្រួតពិនិត្យគ្រប់កម្រិតទាំងអស់នៃអាជ្ញាធររដ្ឋបាលខេត្តត្រួតពិនិត្យប៉ូលីសជាតិ ការពារសណ្តាប់ធ្នាប់ និងសន្តិសុខសង្គម និងផ្តល់សុវត្ថិភាពជូនប្រជារាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា។

ចំនួនមន្ត្រីក្នុងអង្គភាពស្ថិតិដែលបានចាត់តាំង ៖ ៣០ នាក់

ថវិកាប៉ាន់ស្មានសម្រាប់អង្គភាពស្ថិតិដែលបានចាត់តាំង ៖ គ្មានចម្លើយ

ស្ថិតិផ្លូវការដែលបានចាត់តាំងរបស់ក្រសួងមហាផ្ទៃ ដែលទទួលខុសត្រូវ ៖

- ស្ថិតិប្រជាពលរដ្ឋ ប្រចាំឆ្នាំ
- ស្ថិតិអត្តសញ្ញាណប័ណ្ណ ប្រចាំឆ្នាំ
- ស្ថិតិការចុះបញ្ជីអគ្រានុកូលដ្ឋាន ប្រចាំឆ្នាំ
- ស្ថិតិបទល្មើសព្រហ្មទណ្ឌ និងការបង្ក្រាប ប្រចាំឆ្នាំ
- ស្ថិតិជនជាប់ឃុំ និងការអប់រំកែប្រែ ប្រចាំឆ្នាំ
- ស្ថិតិជនអន្តោប្រវេសន៍ ប្រចាំឆ្នាំ
- ស្ថិតិគណៈបក្សនយោបាយ ប្រចាំឆ្នាំ
- ស្ថិតិអង្គការមិនមែនរដ្ឋាភិបាល ប្រចាំឆ្នាំ
- ស្ថិតិការបង្កើតក្រុង ស្រុក ខណ្ឌ សង្កាត់ ឃុំ និងភូមិថ្មី។

### ស្ថិតិផ្លូវការដែលបានចាត់តាំងបោះពុម្ពផ្សាយ ដោយក្រសួងមហាផ្ទៃ

| ឈ្មោះស្ថិតិ | គ្រាគោល | ទិន្នន័យបោះពុម្ពផ្សាយចុងក្រោយ | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិប្រជាពលរដ្ឋ | ២០០៩ | ២០១០ | របាយការណ៍បូកសរុបឆ្នាំ ២០០៩ និងទិសដៅការងារឆ្នាំ ២០១០ |
| ស្ថិតិអត្តសញ្ញាណប័ណ្ណ | ២០០៩ | ២០១០ | របាយការណ៍បូកសរុបឆ្នាំ ២០០៩ និងទិសដៅការងារឆ្នាំ ២០១០ |
| ស្ថិតិការចុះបញ្ជីអគ្រានុកូលដ្ឋាន | ២០០៩ | ២០១០ | របាយការណ៍បូកសរុបឆ្នាំ ២០០៩ និងទិសដៅការងារឆ្នាំ ២០១០ |
| ស្ថិតិបទល្មើសព្រហ្មទណ្ឌ | ២០០៩ | ២០១០ | របាយការណ៍បូកសរុបឆ្នាំ ២០០៩ និងទិសដៅ |

| | | | |
|---|---|---|---|
| និងការបង្ក្រាប | | | ការងារឆ្នាំ ២០១០ |
| ស្ថិតិជនជាប់ឃុំ និងការអប់រំកែប្រែ | ២០០៩ | ២០១០ | របាយការណ៍បូកសរុបឆ្នាំ ២០០៩ និងទិសដៅការងារឆ្នាំ ២០១០ |
| ស្ថិតិជនអន្តោប្រវេសន៍ | ២០០៩ | ២០១០ | របាយការណ៍បូកសរុបឆ្នាំ ២០០៩ និងទិសដៅការងារឆ្នាំ ២០១០ |
| ស្ថិតិគណៈបក្សនយោបាយ | ២០០៩ | ២០១០ | របាយការណ៍បូកសរុបឆ្នាំ ២០០៩ និងទិសដៅការងារឆ្នាំ ២០១០ |
| ស្ថិតិអង្គការមិនមែនរដ្ឋាភិបាល | ២០០៩ | ២០១០ | របាយការណ៍បូកសរុបឆ្នាំ ២០០៩ និងទិសដៅការងារឆ្នាំ ២០១០ |
| ស្ថិតិការបង្កើតក្រុង ស្រុក ខណ្ឌ សង្កាត់ ឃុំ និងភូមិថ្មី | ២០០៩ | ២០១០ | របាយការណ៍បូកសរុបឆ្នាំ ២០០៩ និងទិសដៅការងារឆ្នាំ ២០១០ |

## ៦.៤.៤ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ភារកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺបំពេញបេសកកម្មណែនាំ និងគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជាដើម្បីគាំទ្រការអភិវឌ្ឍន៍សេដ្ឋកិច្ច និងធ្វើឲ្យប្រសើរឡើងនូវកម្រិតជីវភាពរបស់ប្រជាពលរដ្ឋកម្ពុជា ដោយផ្អែកលើគោលការណ៍សេដ្ឋកិច្ចទីផ្សារសេរី និងសមភាពសង្គម។

ចំនួនមន្ត្រីក្នុងអង្គភាពស្ថិតិដែលបានចាត់តាំង ៖ ៣៤ នាក់

ថវិកាប៉ាន់ស្មានសម្រាប់អង្គភាពស្ថិតិដែលបានចាត់តាំង ៖ ៣៩.៨០៤ ដុល្លារអាមេរិក

ស្ថិតិផ្លូវការដែលបានចាត់តាំងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលទទួលខុសត្រូវ ៖

- ស្ថិតិហិរញ្ញវត្ថុរាជរដ្ឋាភិបាល ប្រចាំខែ និងប្រចាំឆ្នាំ
- ស្ថិតិបំណុលសាធារណៈ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- ស្ថិតិការអនុវត្តថវិការាជរដ្ឋាភិបាល ប្រចាំខែ និងប្រចាំឆ្នាំ
- ស្ថិតិពន្ធដារ ប្រចាំខែ
- ស្ថិតិទំនិញដឹកជញ្ជូន ផ្លូវគោក ផ្លូវដែក ផ្លូវទឹក និងផ្លូវអាកាស ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- ស្ថិតិចំណូលមិនមែនសារពើពន្ធ ប្រចាំឆ្នាំ
- ស្ថិតិពាណិជ្ជកម្មក្រៅប្រទេស ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ។

### ស្ថិតិផ្លូវការដែលបានចាត់តាំងបោះពុម្ពផ្សាយ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

| ឈ្មោះស្ថិតិ | គ្រាគោល | ទិន្នន័យបោះពុម្ពផ្សាយចុងក្រោយ | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិហិរញ្ញវត្ថុរាជរដ្ឋាភិបាល | ២០១០ | ២០១១ | ការអនុវត្តន៍ថវិការដ្ឋ ខែ ធ្នូ ឆ្នាំ ២០១០ |
| ស្ថិតិបំណុលសាធារណៈ | ២០១០ | ២០១១ | ការអនុវត្តន៍ថវិការដ្ឋ ខែ ធ្នូ ឆ្នាំ ២០១០ |

| | | | |
|---|---|---|---|
| ស្ថិតិការអនុវត្តថវិការាជរដ្ឋាភិបាល | ២០១០ | ២០១១ | ការអនុវត្តន៍ថវិការដ្ឋ ខែ ធ្នូ ឆ្នាំ ២០១០ |
| ស្ថិតិពន្ធដារ | ២០១០ | ២០១១ | ការអនុវត្តន៍ថវិការដ្ឋ ខែ ធ្នូ ឆ្នាំ ២០១០ |
| ស្ថិតិទំនិញដឹកជញ្ជូន ផ្លូវគោក ផ្លូវដែក ផ្លូវទឹក និងផ្លូវអាកាស | - | - | - |
| ស្ថិតិចំណូលមិនមែនសារពើពន្ធ | ២០១០ | ២០១១ | ការអនុវត្តន៍ថវិការដ្ឋ ខែ ធ្នូ ឆ្នាំ ២០១០ |
| ស្ថិតិពាណិជ្ជកម្មក្រៅប្រទេស | ២០១០ | ២០១១ | ការអនុវត្តន៍ថវិការដ្ឋ ខែ ធ្នូ ឆ្នាំ ២០១០ |

### ៦.៤.៥ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានមុខងារ និងភារកិច្ច ៖

- រៀបចំ និងដាក់ឲ្យដំណើរការ នយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម ក្នុងគោលបំណងកែលម្អកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។
- ចូលរួមក្នុងការរៀបចំគោលនយោបាយកែទម្រង់ និងប្រើប្រាស់ដីធ្លី។
- តម្រង់ទិស និងធ្វើផែនការ អភិវឌ្ឍន៍វិស័យកសិកម្មគ្រប់ផ្នែក។
- សម្របសម្រួល តាមដាន និងវាយតម្លៃ លើការអនុវត្តន៍នយោបាយ និងសកម្មភាពអភិវឌ្ឍន៍កសិកម្ម។
- តាមដានការវិវត្តន៍នៃធនធានធម្មជាតិ របស់វិស័យកសិកម្ម និងសម្រួលដល់ការធ្វើអាជីវកម្មធនធានធម្មជាតិទាំងនោះ ដើម្បីបំពេញតម្រូវការរបស់ប្រទេសជាតិ និងគោរពលំនឹងអេកូឡូស៊ី។
- កំណត់បទប្បញ្ញត្តិក្នុងការគ្រប់គ្រង ថែរក្សា ការពារធនធានធម្មជាតិរបស់វិស័យកសិកម្ម និងតាមដានការអនុវត្ត។
- វាយតម្លៃ និងបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ចូលរួមក្នុងការអភិវឌ្ឍន៍កសិកម្មដោយលើកកម្ពស់កម្រិតយល់ដឹងបច្ចេកទេស និងបង្កលក្ខណៈប្រើប្រាស់ធនធាននេះ ឲ្យមានប្រសិទ្ធភាព។
- ផ្តល់ការគាំទ្រ និងការណែនាំបច្ចេកទេសជាចាំបាច់ដល់កសិករ ដើម្បីកែលម្អផលិតកម្ម និងផលិតភាពកសិកម្ម ។
- កំណត់គោលការណ៍ និងតាមដានការអនុវត្ត លើកកម្ពស់ និងកែលម្អដំណើរប្រព្រឹត្តទៅរបស់អង្គការវិជ្ជាជីវៈ សមាគមនានា ដែលពាក់ព័ន្ធ និងវិស័យកសិកម្ម។
- សិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយអំពីវិទ្យាសាស្ត្របច្ចេកទេស និងសេដ្ឋកិច្ច ក្នុងវិស័យកសិកម្មគ្រប់ផ្នែក។
- ណែនាំការងារអភិវឌ្ឍន៍ដី និងការកែលម្អគុណភាពដី និងប្រើប្រាស់ដីកសិកម្ម ពូជរុក្ខជាតិ ពូជសត្វ ជីគីមី និងថ្នាំកសិកម្មឲ្យបានសមស្រមទៅតាមលក្ខណៈភូមិសាស្ត្រ អាកាសធាតុរបស់តំបន់ ដើម្បីធានាបានទិន្នផលខ្ពស់ និងរក្សាតុល្យភាពបរិស្ថាន ធម្មជាតិ។
- ធ្វើសហការជាតិ និងសហប្រតិបត្តិការជាមួយបរទេស អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មគ្រប់ផ្នែក។

ចំនួនមន្ត្រីក្នុងអង្គភាពស្ថិតិដែលបានចាត់តាំង ៖ ៨ នាក់

ថវិកាប៉ាន់ស្មានសម្រាប់អង្គភាពស្ថិតិដែលបានចាត់តាំង ៖ ៣០.០០០ ដុល្លារអាមេរិក

ស្ថិតិផ្លូវការដែលបានចាត់តាំងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលទទួលខុសត្រូវ ៖

- ស្ថិតិថ្លៃទំនិញកសិកម្ម ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- ស្ថិតិអង្កេតផ្ទៃដី ទិន្នផល និងបរិមាណផលដំណាំ ប្រចាំរដូវ និងប្រចាំឆ្នាំ
- ស្ថិតិផលិតកម្ម និងបសុព្យាបាល ប្រចាំឆ្នាំ
- ស្ថិតិជលផល ប្រចាំឆ្នាំ
- ស្ថិតិព្រៃឈើ ប្រចាំឆ្នាំ
- ស្ថិតិផលិតកម្មដំណាំកៅស៊ូ ប្រចាំឆ្នាំ
- ស្ថិតិគ្រឿងយន្តកសិកម្ម ប្រចាំឆ្នាំ
- ស្ថិតិថ្នាំកសិកម្ម និងសម្ភារៈកសិកម្ម ប្រចាំឆ្នាំ។

## ស្ថិតិផ្លូវការដែលបានចាត់តាំងបោះពុម្ពផ្សាយ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| ឈ្មោះស្ថិតិ | គ្រាគោល | ទិន្នន័យបោះពុម្ពផ្សាយចុងក្រោយ | ឈ្មោះរបាយការណ៍ចុងក្រោយ |
|---|---|---|---|
| ស្ថិតិតម្លៃទំនិញកសិកម្ម | ២០១០ | ២០១១ | របាយការណ៍ឆ្នាំ ២០១០-២០១១ និងទិសដៅ ឆ្នាំ ២០១១-២០១២ |
| ស្ថិតិអង្កេតផ្ទៃដី ទិន្នផល និងបរិមាណផលដំណាំ | ២០១០ | ២០១១ | របាយការណ៍ឆ្នាំ ២០១០-២០១១ និងទិសដៅ ឆ្នាំ ២០១១-២០១២ |
| ស្ថិតិផលិតកម្ម និងបសុព្យាបាល | ២០១០ | ២០១១ | របាយការណ៍ឆ្នាំ ២០១០-២០១១ និងទិសដៅ ឆ្នាំ ២០១១-២០១២ |
| ស្ថិតិជលផល | ២០១០ | ២០១១ | របាយការណ៍ឆ្នាំ ២០១០-២០១១ និងទិសដៅ ឆ្នាំ ២០១១-២០១២ |
| ស្ថិតិព្រៃឈើ | ២០១០ | ២០១១ | របាយការណ៍ឆ្នាំ ២០១០-២០១១ និងទិសដៅ ឆ្នាំ ២០១១-២០១២ |
| ស្ថិតិផលិតកម្មដំណាំកៅស៊ូ | ២០១០ | ២០១១ | របាយការណ៍ឆ្នាំ ២០១០-២០១១ និងទិសដៅ ឆ្នាំ ២០១១-២០១២ |
